LP មីក្រូហិរញ្ញវត្ថុ ម.ក
Microfinance Plc

# របាយការណ៍
# ប្រចាំឆ្នាំ២០២៣

**I. ប្រវត្តិគ្រឹះស្ថាន វ៉ាយ.អិល.ភី**
១. ទស្សនវិស័យ និងបេសកកម្ម
២. ព័ត៌មានហិរញ្ញវត្ថុសង្ខេប
៣. សេចក្ដីសង្ខេបអំពី "វ៉ាយ.អិល.ភី

**II. អភិបាលកិច្ច**
១. ចំណាប់អារម្មណ៍ប្រធានក្រុមប្រឹក្សាភិបាល
២. ចំណាប់អារម្មណ៍អគ្គនាយក
៣. សមាជិកក្រុមប្រឹក្សាភិបាល
៤. ភាគទុនិក
៥. គណៈគ្រប់គ្រង
៦. រចនាសម្ព័ន្ធគ្រប់គ្រង

**III. និន្នាការទូទៅនៃសេដ្ឋកិច្ចកម្ពុជា**

**IV. ផលិតផល និងសេវាកម្ម**
១. ប្រភេទផលិតផល
២. ផលបត្រឥណទាន
៣. ចំណាប់អារម្មណ៍អតិថិជន

**V. គណៈកម្មាធិការគ្រប់គ្រងគ្រឹះស្ថាន**

**ក. កម្រិតក្រុមប្រឹក្សាភិបាល**
១. គណៈកម្មាធិការក្រុមប្រឹក្សាភិបាល
២. គណៈកម្មាធិការគ្រប់គ្រងហានិភ័យ
៣. គណៈកម្មាធិការសវនកម្ម

**ខ. កម្រិតគណៈគ្រប់គ្រង**
១. គណៈកម្មាធិការប្រតិបត្តិ
២. គណៈកម្មាធិការធនធានមនុស្ស
៣. គណៈកម្មាធិការឥណទាន
៤. គណៈកម្មាធិការគ្រប់គ្រងព័ត៌មានវិទ្យា
៥. គណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម
៦. ការគ្រប់គ្រងហានិភ័យ
៧. ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម
៨. ការត្រួតពិនិត្យផ្ទៃក្នុង

**VI. ការគ្រប់គ្រងធនធានមនុស្ស**
១. ការជ្រើសរើសបុគ្គលិក
២. ការអភិវឌ្ឍសមត្ថភាពបុគ្គលិក
៣. ការវាយតម្លៃ និងការតែងតាំងបុគ្គលិក

**VII. ការចូលរួមជាមួយសង្គម និងការការពារបរិស្ថាន**
១. ការចូលរួមជាមួយសង្គម
២. ការការពារបរិស្ថាន
៣. ការចូលរួមថែរក្សាវប្បធម៌ប្រពៃណីខ្មែរ

**VIII. របាយការណ៍ហិរញ្ញវត្ថុ (សវនកម្ម)**
១. របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ
២. របាយការណ៍លទ្ធផលលម្អិត
៣. របាយការណ៍ស្ដីពីបម្រែបម្រួលមូលធន
៤. របាយការណ៍លំហូរសាច់ប្រាក់

**IX. បណ្ដាញការិយាល័យប្រតិបត្តិការ**

# I. ប្រវត្តិគ្រឹះស្ថាន វ៉ាយ.អិល.ភី

## ១. ទស្សនវិស័យ និងបេសកកម្ម



### ទស្សនវិស័យ

ជាគ្រឹះស្ថានហិរញ្ញវត្ថុដ៏រឹងមាំ ដើម្បីរួមចំណែកក្នុងការជម្រុញ និងលើកកម្ពស់សេដ្ឋកិច្ចគ្រួសារ និងសង្គមជាតិឱ្យកាន់តែល្អប្រសើរ និងមាននិរន្តរភាព។

### បេសកកម្ម

គ្រឹះស្ថាន វ៉ាយ.អិល.ភី មីក្រូហិរញ្ញវត្ថុ ម.ក ផ្តល់សេវាកម្មហិរញ្ញវត្ថុដ៏ល្អប្រសើរ ដែលមានភាពបត់បែនជូនដល់សហគ្រិនខ្នាតតូច-មធ្យម និងនីតិបុគ្គលទូទៅ ដើម្បីប្រើប្រាស់ និងចាត់ចែងហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធិភាពខ្ពស់។



## ២. ព័ត៌មានហិរញ្ញវត្ថុសង្ខេប

គិតត្រឹមថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២៣
(ទិន្នន័យគិតជាលានរៀល)

**ខាតសុទ្ធ**




**សម្ភាធឥណទាន**




**ទ្រព្យសកម្មសរុប**




**មូលធនសរុប**



## ៣. សេចក្តីសង្ខេបអំពី វ៉ាយ.អិល.ភី




គ្រឹះស្ថាន វ៉ាយ.អិល.ភី មីក្រូហិរញ្ញវត្ថុ ម.ក គឺជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលទទួលបានអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា និងបានចុះបញ្ជីត្រឹមត្រូវនៅក្រសួងពាណិជ្ជកម្មលេខ ០០០៤៩២៦៥ ជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកំរិត។ គ្រឹះស្ថាន វ៉ាយ.អិល.ភី មីក្រូហិរញ្ញវត្ថុ ម.ក ត្រូវបានបង្កើតឡើងនៅចុងឆ្នាំ២០១៩ ដែលមានការិយាល័យកណ្ដាលនៅរាជធានីភ្នំពេញ ដោយភាគទុនិកក្នុងស្រុកជាជនជាតិខ្មែរចំនួន ៦រូប ក្នុងគោលបំណងដើម្បីផ្ដល់ប្រភពហិរញ្ញវត្ថុបន្ថែម ដល់ប្រជាជនដែលរស់នៅខេត្តបន្ទាយមានជ័យ។ ប៉ុន្តែដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ គ្រឹះស្ថានបានពន្យាពេលនៃការចាប់ផ្ដើមធ្វើប្រតិបត្តិការរបស់ខ្លួនរហូតដល់ដើមឆ្នាំ២០២២។ នៅថ្ងៃទី ០២ ខែកុម្ភៈ ឆ្នាំ២០២២ គ្រឹះស្ថានបានចាប់ផ្ដើមធ្វើប្រតិបត្តិការដំបូងរបស់ខ្លួននៅតែក្នុងក្រុងសិរីសោភ័ណទីរួមខេត្តបន្ទាយមានជ័យ និងប្រាំបួនខែក្រោយមក គ្រឹះស្ថានបានពង្រីកតំបន់ប្រតិបត្តិការរបស់ខ្លួននៅគ្រប់ស្រុក-ក្រុងទូទាំងខេត្ត(ទាំង៩ ក្រុង-ស្រុក) ដើម្បីបង្ករលក្ខណងាយស្រួលដល់ប្រជាជនក្នុងខេត្តក្នុងការទទួលបាននូវសេវាកម្មហិរញ្ញវត្ថុថ្មី ដែលអាចយកទៅប្រើប្រាស់ក្នុងការស្តារ និងពង្រីកមុខរបររបស់ខ្លួនបន្ទាប់ពីរាជរដ្ឋាភិបាលបានបើកប្រទេសឡើងវិញ ក្រោយមានភាពធូរស្រាលនៃជំងឺកូវីដ-១៩។ គោលដៅចម្បងរបស់ភាគទុនិកក្នុងការបង្កើតគ្រឹះស្ថាន វ៉ាយ.អិល.ភី គឺដើម្បីផ្ដល់ជាប្រភពទុនដល់ប្រជាកសិករ និងអាជីវករតូចតាចក្នុងខេត្តអាចខ្ចីប្រាក់បានក្នុងអត្រាការប្រាក់ទាបសមរម្យ សម្រាប់បង្កើតមុខរបរផ្ទាល់ខ្លួននៅក្នុងស្រុក ជៀសវាងការធ្វើចំណាកស្រុក ដែលអាចជួបប្រទះនឹងហានិភ័យផ្សេងៗ។

# II. អភិបាលកិច្ច

## ១. ចំណាប់អារម្មណ៍ប្រធានក្រុមប្រឹក្សាភិបាល



ក្នុងកំឡុងឆ្នាំ២០២៣ សេដ្ឋកិច្ចប្រទេសកម្ពុជានៅតែអាចបន្តងើបឡើងវិញបាននូវអត្រាកំណើន ៥,៦% ចាប់តាំងពីមានភាពធូរស្បើយការរីករាលដាលនៃជំងឺកូវីដ-១៩ បើទោះបីជាមានការថយចុះនូវតម្រូវការសកល និងការថយចុះនៃវិស័យអចលនទ្រព្យក៏ដោយ។ អត្រាកំណើនសេដ្ឋកិច្ចបានកើនឡើងខ្ពស់ជាងបើប្រៀបធៀបជាមួយឆ្នាំ២០២២(៥,២%) និងឆ្នាំ២០២១ (៣%) ដែលកំណើននេះបានមកពីការងើបឡើងវិញនៃវិស័យសេវាកម្ម និងការនាំចេញទំនិញ ថ្វីបើតម្រូវការក្នុងស្រុកបានធ្លាក់ចុះ និងប្រឈមនឹងវិបត្តិសកលក៏ដោយ។ យោងតាមរបាយការណ៍របស់ធនាគារពិភពលោក សេដ្ឋកិច្ចប្រទេសកម្ពុជាអាចនឹងកើនដល់ ៥,៨% នៅក្នុងឆ្នាំ២០២៤នេះ ហើយអាចនឹងប្រសើរឡើងថែមទៀតនៅឆ្នាំ២០២៥ ឡើងដល់ ៦,១% និងនៅឆ្នាំ២០២៦ ឡើងដល់ ៦,៤% ដោយសារការប្រសើរឡើងវិញលើការនាំចេញវិស័យកាត់ដេរ និងកម្មន្តសាល រួមទាំងការងើបឡើងវិញនៃវិស័យទេសចរណ៍។

រាជរដ្ឋាភិបាលកម្ពុជាបានធ្វើការគ្រប់គ្រង និងចាត់ចែងបានល្អទៅលើម៉ាក្រូសេដ្ឋកិច្ច និងបានដាក់ចេញនូវវិធានការសំខាន់ៗមួយចំនួន ដើម្បីស្តារសេដ្ឋកិច្ចជាតិឡើងវិញ ក្នុងនោះរួមមានការដាក់ចេញនូវវិធានការយ៉ាងតឹងរឹងក្នុងការការពារសុខមាលភាព និងសុវត្ថិភាពរបស់ប្រជាពលរដ្ឋ ក្នុងគោលបំណងកាត់បន្ថយនូវផលប៉ះពាល់អវិជ្ជមានដល់សេដ្ឋកិច្ចជាតិ ជាពិសេសអាជីវកម្មរបស់ប្រជាពលរដ្ឋ។ ទន្ទឹមនឹងនេះ ផែនការយុទ្ធសាស្ត្របញ្ចកោណរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលបានកំណត់គោលដៅរយៈពេលវែងយ៉ាងច្បាស់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមនាពេលអនាគត ដោយផ្តោតលើអាទិភាពសំខាន់ៗចំនួន ៥ គឺ មូលធនមនុស្ស ផ្លូវថ្នល់ ទឹក ភ្លើង និងបច្ចេកវិទ្យា។

ដោយមើលឃើញថា ស្ថានភាពសេដ្ឋកិច្ចនៅឆ្នាំ២០២៣ បានត្រលប់មករកស្ថានភាពល្អវិញបន្តិចម្តងៗ គ្រឹះស្ថាន វ៉ាយ.អិល.ភី មីក្រូហិរញ្ញវត្ថុ ម.ក បានពង្រីកប្រតិបត្តិការហិរញ្ញវត្ថុរបស់ខ្លួនបន្ថែមទៀតនៅក្នុងខេត្តបន្ទាយមានជ័យ ដោយភាពប្រយ័ត្នប្រយែង និងយកចិត្តទុកដាក់បំផុត ដើម្បីការពារ និងគ្រប់គ្រងបាននូវរាល់ហានិភ័យដែលអាចកើតឡើងជាយថាហេតុ។ ជាលទ្ធផលក្នុងឆ្នាំ២០២៣នេះ ដែលជាឆ្នាំទី២របស់ខ្លួន គ្រឹះស្ថាន វ៉ាយ.អិល.ភី មីក្រូហិរញ្ញវត្ថុ ម.ក សម្រេចបាននូវលទ្ធផលអាជីវកម្មដ៏ល្អប្រសើរ ដោយបានផ្តល់ប្រាក់កម្ចីជូនអតិថិជនបានចំនួន ៣៥៥នាក់ ដែលមានទឹកប្រាក់សរុបចំនួន ៣.០៩៥.៣៨៩ ដុល្លារ និងមានផលបត្រឥណទានសរុបចំនួន ៦.៣៨១.៤៣៦ ដុល្លារ និងអតិថិជនសកម្មសរុបចំនួន ៨០៩នាក់។ ក្នុងឆ្នាំនេះដែរ គ្រឹះស្ថានមានការិយាល័យប្រតិបត្តិការចំនួន ៣កន្លែង និងមានបុគ្គលិកសរុបចំនួន ៦៦នាក់ ហើយបុគ្គលិកទាំងអស់បានយកចិត្តទុកដាក់ក្នុងការអភិវឌ្ឍខ្លួនទាំងចំណេះ ជំនាញ និងស្វែងយល់ពីតម្រូវការចាំបាច់របស់អតិថិជន ដើម្បីបម្រើសេវាកម្មជូនអតិថិជនឱ្យកាន់តែប្រសើរឡើង និងមានភាពបត់បែនក្នុងបរិបទថ្មី។

គ្រឹះស្ថាន វ៉ាយ.អិល.ភី មីក្រូហិរញ្ញវត្ថុ ម.ក មានការប្តេជ្ញាចិត្តយ៉ាងម៉ឺងម៉ាត់ក្នុងការផ្តល់សេវាកម្មជូនអតិថិជនប្រកបដោយតម្លាភាព និងជឿទុកចិត្តស្របទៅតាមគោលការណ៍ការពារអតិថិជន។ គ្រឹះស្ថានក៏បានបន្តយកចិត្តទុកដាក់ពង្រឹងការគ្រប់គ្រង និងការចូលរួមរបស់បុគ្គលិកបានយ៉ាងល្អដោយមានទំនួលខុសត្រូវ ហើយយើងរំពឹងថានឹងបន្តការរីកចម្រើនទៅមុខនៅក្នុងឆ្នាំ២០២៤-២០២៥។ គ្រឹះស្ថានបានផ្តោតការយកចិត្តទុកដាក់លើអតិថិ

ជនគោលដៅរបស់ខ្លួន ជាពិសេសផ្នែកអាជីវកម្មលក់រាយមានដូចជា៖ អាជីវកម្មខ្នាតតូចបំផុត-តូច-មធ្យម មុខរបរកសិកម្ម កម្មករនិយោជិត មន្ត្រីរាជការ និងអាជីវករ។

លើសពីនេះ គ្រឹះស្ថាន វ៉ាយ.អិល.ភី មីក្រូហិរញ្ញវត្ថុ ម.ក ប្តេជ្ញាចិត្តថានឹងបន្តតួនាទីយ៉ាងសំខាន់ ដើម្បីចូលរួមក្នុងការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋកម្ពុជាឱ្យកាន់តែល្អប្រសើរឡើង និងបន្តចូលរួមចំណែកកំណត់ស្តង់ដារទទួលខុសត្រូវសង្គមសម្រាប់វិស័យទាំងមូលនៅក្នុងប្រទេសកម្ពុជា។

សូមអរគុណ!

លោកស្រី **ម៉ៅ ម៉ាល័យ**

**ប្រធានក្រុមប្រឹក្សាភិបាល**

## ២. ចំណាប់អារម្មណ៍អគ្គនាយក



ក្នុងនាមជាអគ្គនាយកនៃគ្រឹះស្ថាន វ៉ាយ.អិល.ភី មីក្រូហិរញ្ញវត្ថុ ម.ក ខ្ញុំមានសេចក្តីសោមនស្សរីករាយ ក្នុងការចែករំលែកជាមួយអ្នកនូវចំណុចសំខាន់ៗ និងសមិទ្ធផលមួយចំនួនរបស់គ្រឹះស្ថានកន្លងមក និងការតាំងចិត្តសម្រាប់ថ្ងៃអនាគត។

ក្នុងឆ្នាំ២០២៣ នេះគឺជាឆ្នាំដ៏លំបាកមួយសម្រាប់គ្រឹះស្ថាន វ៉ាយ.អិល.ភី មីក្រូហិរញ្ញវត្ថុ ម.ក ដោយសារយើងប្រឈមមុខនឹងផលប៉ះពាល់នៃការប្រែប្រួលសេដ្ឋកិច្ចសកល និងការផ្លាស់ប្តូរលក្ខខណ្ឌទីផ្សារ ប៉ុន្តែនេះក៏ជាឆ្នាំដែលគ្រឹះស្ថានសម្រេចបាននូវសមិទ្ធផលជាច្រើនផងដែរ ។ គ្រឹះស្ថាន វ៉ាយ.អិល.ភី មីក្រូហិរញ្ញវត្ថុ ម.ក បានបន្តអនុវត្តគោលដៅចម្បង និងយុទ្ធសាស្ត្ររបស់ខ្លួន ដើម្បីក្លាយជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលឈានមុខគេក្នុងខេត្ត និងអាចជួយបង្កើនជីវភាពរស់នៅរបស់ប្រជាជន តាមរយៈការផ្តល់ឥណទានមានច្រើនជម្រើសជូនអតិថិជនក្នុងការបំពេញនូវតម្រូវការផ្នែកហិរញ្ញវត្ថុ សម្រាប់បម្រើ និងបំពេញតម្រូវការប្រចាំថ្ងៃ ចូលរួមចំណែកក្នុងការអភិវឌ្ឍមូលដ្ឋាន និងប្រទេសជាតិ ស្របតាមគោលនយោបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល។

នៅក្នុងឆ្នាំ២០២៣ គ្រឹះស្ថាន វ៉ាយ.អិល.ភី មីក្រូហិរញ្ញវត្ថុ ម.ក សម្រេចបាននូវលទ្ធផលហិរញ្ញវត្ថុសំខាន់ៗដូចជា ទ្រព្យសកម្មសរុបមានចំនួន ៧.០៥០.០០២ ដុល្លារ សមតុល្យឥណទានសរុបមានចំនួន ៦.៣៨១.៤៣៦ ដុល្លារ អតិថិជនសកម្មសរុបមានចំនួន ៨០៩នាក់ និងចំណូលប្រតិបត្តិការសរុបមានចំនួន ៨៨០.៩២៨ ដុល្លារ។ ទន្ទឹមនឹងនេះ គ្រឹះស្ថានយើងបានទទួលការយល់ព្រមពីធនាគារជាតិនៃកម្ពុជានៅថ្ងៃទី ០៤ ខែតុលា ឆ្នាំ២០២៣ សម្រាប់ប្រតិបត្តិការសេវាកម្មប្តូរប្រាក់ ដើម្បីបំពេញតម្រូវការអតិថិជន។ លើសពីនេះ គ្រឹះស្ថាន វ៉ាយ.អិល.ភី មីក្រូហិរញ្ញវត្ថុ ម.ក បានចូលរួមចំណែកក្នុងសកម្មភាពសង្គម និងសហគមន៍ជាច្រើនដូចជា៖ បានចូលរួមឧបត្ថម្ភដល់ក្រុមកីឡាករអុំទូកនៅខេត្តបន្ទាយមានជ័យ ការចូលរួមឧបត្ថម្ភជាសាច់ប្រាក់ដល់កាកបាទក្រហមកម្ពុជា ការឧបត្ថម្ភដល់អាជ្ញាធរមូលដ្ឋាន និងសភាពសហព័ន្ធយុវជនខេត្តបន្ទាយមានជ័យជាដើម។ សមិទ្ធផលទាំងនេះនឹងមិនអាចសម្រេចទៅបានទេប្រសិនបើគ្មានការជឿទុកចិត្ត និងការគាំទ្រពីសំណាក់អតិថិជន ដៃគូរហសការ និងអាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់។

ក្នុងនាមជាអគ្គនាយកនៃគ្រឹះស្ថាន វ៉ាយ.អិល.ភី មីក្រូហិរញ្ញវត្ថុ ម.ក ខ្ញុំសូមថ្លែងអំណរគុណដល់ម្ចាស់ភាគហ៊ុន ថ្នាក់គ្រប់គ្រង និងបុគ្គលិកទាំងអស់ ជាពិសេសក្រុមប្រឹក្សាភិបាល សម្រាប់ការគាំទ្រ និងផ្តល់ជាយុទ្ធសាស្ត្រល្អៗជាច្រើន ដែលធ្វើឱ្យគ្រឹះស្ថានដំណើរការទៅដោយរលូន និងមានប្រសិទ្ធភាពខ្ពស់។ យើងនឹងបន្តស្វែងរកចក្ខុវិស័យ និងគុណតម្លៃថ្មីៗបន្ថែមទៀត ដើម្បីផ្តល់នូវដំណោះស្រាយសេវាកម្មហិរញ្ញវត្ថុដ៏ល្អបំផុតសម្រាប់អ្នក។

ជាចុងក្រោយ ខ្ញុំក៏សូមថ្លែងអំណរគុណដល់រាជរដ្ឋាភិបាលកម្ពុជា ធនាគារជាតិនៃកម្ពុជា និយតកម្ម អាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ និងអតិថិជនទាំងអស់ដែលតែងតែគាំទ្រដល់គ្រឹះស្ថាន វ៉ាយ.អិល.ភី មីក្រូហិរញ្ញវត្ថុ ម.ក កន្លងមក។ សូមអរគុណ!

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ វ៉ាយ អិល ភី មីក្រូហិរញ្ញវត្ថុ ម.ក
Y L P MICROFINANCE PLC
KINGDOM OF CAMBODIA

លោក **កែ សួនសុភា**

**អគ្គនាយក**

## ៣. សមាជិកក្រុមប្រឹក្សាភិបាល

### លោកស្រី ម៉ៅ ម៉ាល័យ

### ប្រធានក្រុមប្រឹក្សាភិបាលនៃគ្រឹះស្ថាន វ៉ាយ.អិល.ភី មីក្រូហិរញ្ញវត្ថុ ម.ក



លោកស្រី **ម៉ៅ ម៉ាល័យ** ជាស្ថាបនិក និងជាប្រធានក្រុមប្រឹក្សាភិបាលនៃគ្រឹះស្ថាន វ៉ាយ.អិល.ភី មីក្រូហិរញ្ញវត្ថុ ម.ក ដែលទទួលស្គាល់ដោយធនាគារជាតិនៃកម្ពុជា ចាប់តាំងពីថ្ងៃទី ១៩ ខែសីហា ឆ្នាំ២០១៩។ ក្នុងតួនាទីជាប្រធានក្រុមប្រឹក្សាភិបាល លោកស្រីបានធ្វើការងារជាច្រើន ក្នុងការកំណត់ផែនការគោលដៅ យុទ្ធសាស្ត្រ និងគោលនយោបាយផ្សេងៗ ដើម្បីធានាបាននូវនិរន្តរភាព ការគ្រប់គ្រងហានិភ័យ និងការអនុវត្តត្រឹមត្រូវតាមគោលការណ៍ច្បាប់របស់ធនាគារជាតិនៃកម្ពុជា មានដូចជា៖

- ដឹកនាំបង្កើតអោយមានប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងសមស្រប និងអនុលោម តាមបទប្បញ្ញត្តិនៃច្បាប់។
- ដឹកនាំក្នុងការរៀបចំផែនការ យុទ្ធសាស្ត្រ និងកំណត់គោលមាគ៌ារបស់គ្រឹះស្ថានវ៉ាយ.អិល.ភី មីក្រូហិរវត្ថុ ម.ក។
- បង្កើតគណៈកម្មាធិការជាន់ខ្ពស់ និងតែងតាំងសមាជិកភាព និងកំណត់ច្បាស់លាស់នូវមុខងារតួនាទី និងភារកិច្ចរបស់គណៈកម្មាធិការនីមួយៗ។
- ដឹកនាំ ត្រួតពិនិត្យ និងវាយតម្លៃអំពីវឌ្ឍនភាពរបស់គ្រឹះស្ថានជាប្រចាំ ដើម្បីធ្វើការពង្រឹង និងកែលម្អបានទាន់ពេលវេលា។
- ដឹកនាំបង្កើតឱ្យមានគោលនយោបាយ និងគោលការណ៍ប្រតិបត្តិផ្សេងៗដូចជា៖ គោលនយោបាយឥណទាន គោលនយោបាយហិរញ្ញវត្ថុ គោលការណ៍ប្រតិបត្តិធនធានមនុស្ស និងគោលការណ៍គ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យាជាដើម សម្រាប់ប្រើប្រាស់ និងគ្រប់គ្រងគ្រឹះស្ថាន។

ទន្ទឹមនឹងនេះ លោកស្រី **ម៉ៅ ម៉ាល័យ** ក៏ជាអគ្គនាយកក្រុមហ៊ុន វ៉ាយ.អិល.ភី គ្រុប ខូអិលធីឌី និងជាស្ថាបនិកមណ្ឌលកុមារកំព្រាវិសាខានៃក្តីសង្ឃឹមផងដែរ។

ក្រៅពីការងារគ្រប់គ្រង និងដឹកនាំក្រុមហ៊ុន លោកស្រីក៏បានចូលរួមយ៉ាងសកម្មនៅក្នុងកិច្ចការជួយសង្គម និងកិច្ចការមនុស្សធម៌ជាច្រើន ដោយបានលះបង់ទាំងកំលាំងកាយ កំលាំងចិត្ត ចំណេះបញ្ញា ស្មារតី និងថវិកាផ្ទាល់ខ្លួន ក្នុងការសាងសង់ផ្លូវ សាលារៀន ព្រះវិហារ មណ្ឌលកុមារកំព្រា ផ្តល់សម្ភារសិក្សាដល់សិស្សានុសិស្ស ផ្តល់អំណោយដល់ពលរដ្ឋខ្វះខាត និងចូលរួមឧបត្ថម្ភថវិកាដល់រាជរដ្ឋាភិបាលក្នុងការស្តារ និងអភិវឌ្ឍសេដ្ឋកិច្ចជាដើម។

### លោក កែ សួនសុភា
### សមាជិកក្រុមប្រឹក្សាភិបាលនៃគ្រឹះស្ថាន វ៉ាយ.អិល.ភី មីក្រូហិរញ្ញវត្ថុ ម.ក



លោក **កែ សួនសុភា** ជាស្ថាបនិក និងជាសមាជិកក្រុមប្រឹក្សាភិបាលនៃគ្រឹះស្ថាន វ៉ាយ.អិល.ភី មីក្រូហិរញ្ញវត្ថុ ម.ក ចាប់តាំងពីថ្ងៃទី ១៩ ខែសីហា ឆ្នាំ២០១៩ មក។ ក្នុងតួនាទីជាសមាជិកក្រុមប្រឹក្សាភិបាល លោកបានលះបង់ទាំងកំលាំងកាយចិត្ត កំលាំងប្រាជ្ញា និងចំណេះជំនាញ ដើម្បីចូលរួមក្នុងការបង្កើត និងអភិវឌ្ឍន៍គ្រឹះស្ថានដូចជា៖ ការចូលរួមផ្តល់យោបល់ក្នុងការកំណត់គោលនយោបាយរបស់គ្រឹះស្ថាន ការកំណត់យុទ្ធសាស្ត្រទីផ្សារ ការគ្រប់គ្រង និងការបង្កើតគោលការណ៍ប្រតិបត្តិផ្សេងៗជាច្រើនសម្រាប់អនុវត្តនៅក្នុងគ្រឹះស្ថានទាំងមូល។

ក្រៅពីការងារនៅគ្រឹះស្ថាន វ៉ាយ.អិល.ភី លោក **កែ សួនសុភា** ក៏មានតួនាទីជាអនុប្រធានគណៈកម្មាធិការប្រតិបត្តិរបស់សមាគមមូលនិធិ វ៉ាយ.អិល.ភី និងជាស្ថាបនិកមួយរូប នៃមណ្ឌលកុមារកំព្រាវិសាខានៃក្តីសង្ឃឹមផងដែរ។

### លោកស្រី កែ សួនសុភី
### សមាជិកក្រុមប្រឹក្សាភិបាលនៃគ្រឹះស្ថាន វ៉ាយ.អិល.ភី មីក្រូហិរញ្ញវត្ថុ ម.ក



លោកស្រី **កែ សួនសុភី** ជាស្ថាបនិក និងជាសមាជិកក្រុមប្រឹក្សាភិបាលនៃគ្រឹះស្ថាន វ៉ាយ.អិល.ភី មីក្រូហិរញ្ញវត្ថុ ម.ក ចាប់តាំងពីថ្ងៃទី ១៩ ខែសីហា ឆ្នាំ២០១៩ មក។ ក្នុងតួនាទីជាសមាជិកក្រុមប្រឹក្សាភិបាល លោកស្រីបានលះបង់ទាំងកំលាំងកាយ កំលាំងចិត្ត កំលាំងប្រាជ្ញា និងចំណេះជំនាញ ដើម្បីចូលរួមក្នុងការបង្កើត និងអភិវឌ្ឍន៍គ្រឹះស្ថានដូចជា៖ ការចូលរួមផ្តល់យោបល់ក្នុងការកំណត់គោលនយោបាយរបស់គ្រឹះស្ថាន ការកំណត់យុទ្ធសាស្ត្រទីផ្សារ ការគ្រប់គ្រង និងការបង្កើតគោលការណ៍ប្រតិបត្តិផ្សេងៗជាច្រើនសម្រាប់អនុវត្តនៅក្នុងគ្រឹះស្ថានទាំងមូល។

ក្រៅពីការងារជាសមាជិកក្រុមប្រឹក្សាភិបាលនៃគ្រឹះស្ថាន វ៉ាយ.អិល.ភី មីក្រូហិរញ្ញវត្ថុ ម.ក លោកស្រី **កែ សួនសុភី** ក៏មានតួនាទីជាអ្នកគ្រប់គ្រងកំពូលនៅក្រុមហ៊ុន និងសមាគមជាច្រើនផ្សេងទៀត ដូចជា៖ ជាប្រធានក្លិបបាល់ទាត់វិសាខា ជាប្រធានក្រុមដឹកនាំមូលនិធិវិសាខា ជាប្រធានក្រុមការងារសង្គ្រោះបន្ទាយឆ្មា-ខេត្តបាត់ដំបង-ខេត្តសៀមរាប-ខេត្តព្រៃវែង អមដំណើរប្រធានក្រុមការងារអភិវឌ្ឍន៍យុវជនខេត្តព្រៃវែង និងជាស្ថាបនិកនៅមណ្ឌលកុមារកំព្រាវិសាខានៃក្តីសង្ឃឹម។

លើសពីនេះ លោកស្រី **កែ សួនសុភី** ក៏បានចូលរួមកិច្ចការសង្គម និងកិច្ចការមនុស្សធម៌ជាច្រើន ដោយលះបង់ទាំងកំលាំងកាយ កំលាំងចិត្ត និងថវិកាផ្ទាល់ខ្លួនក្នុងការសាងសង់ផ្លូវ សាលារៀន ព្រះវិហារ ផ្តល់សម្ភារសិក្សាដល់

សិស្សានុសិស្ស ផ្តល់អំណោយដល់ពលរដ្ឋខ្វះខាត និងចូលរួមឧបត្ថម្ភថវិកាដល់រាជរដ្ឋាភិបាលក្នុងការទប់ស្កាត់ជម្ងឺឆ្លងកូវីដ-១៩ ជាដើម។

លោកស្រី **កែ ស្ងួនសុភី** បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ នៅសាកលវិទ្យាល័យក្នុងស្រុក និងបានបន្តការសិក្សានៅក្រៅប្រទេសផងដែរ។

## លោកស្រី ព្រហ្ម រដ្ឋា

### សមាជិកក្រុមប្រឹក្សាភិបាលនៃគ្រឹះស្ថាន វ៉ាយ.អិល.ភី មីក្រូហិរញ្ញវត្ថុ ម.ក



លោកស្រី **ព្រហ្ម រដ្ឋា** ជាស្ថាបនិក និងជាសមាជិកក្រុមប្រឹក្សាភិបាល នៃគ្រឹះស្ថាន វ៉ាយ.អិល.ភី មីក្រូហិរញ្ញវត្ថុ ម.ក ចាប់តាំងពីថ្ងៃទី ១៩ ខែសីហា ឆ្នាំ២០១៩ មក។ ក្នុងតួនាទីជាសមាជិកក្រុមប្រឹក្សាភិបាល លោកស្រីបានលះបង់ទាំងកំលាំងកាយ-ចិត្ត កំលាំងប្រាជ្ញា និងចំណេះជំនាញ ដើម្បីចូលរួមក្នុងការបង្កើត និងអភិវឌ្ឍន៍គ្រឹះស្ថានដូចជា៖ ការចូលរួមផ្តល់យោបល់ក្នុងការកំណត់គោលនយោបាយរបស់គ្រឹះស្ថាន ការកំណត់យុទ្ធសាស្ត្រ ការគ្រប់គ្រង និងការបង្កើតគោលការណ៍-នីតិវិធីប្រតិបត្តិផ្សេងៗជាច្រើនសម្រាប់ប្រើប្រាស់ក្នុងប្រតិបត្តិការរបស់គ្រឹះស្ថាន។

ក្រៅពីការងារនៅគ្រឹះស្ថាន វ៉ាយ.អិល.ភី មីក្រូហិរញ្ញវត្ថុ ម.ក លោកស្រី **ព្រហ្ម រដ្ឋា** ក៏មានតួនាទីជាអ្នកគ្រប់គ្រងនៅស្ថាប័នផ្សេងទៀតដូចជា៖ ជាស្ថាបនិកនៃមណ្ឌលកុមារកំព្រាវិសាខានៃក្តីសង្ឃឹម អមដំណើរប្រធានក្រុមការងារអភិវឌ្ឍន៍យុវជនខេត្តបន្ទាយមានជ័យ និងអមដំណើរប្រធាន ស.ស.យ.ក ខេត្តបន្ទាយមានជ័យ។

លើសពីនេះទៅទៀត លោកស្រីបានចូលរួមកិច្ចការសង្គម និងកិច្ចការមនុស្សធម៌ជាច្រើនទៀត ដោយបានលះបង់ទាំងកំលាំងកាយ កំលាំងចិត្ត និងថវិកាក្នុងការសាងសង់ផ្លូវ សាលារៀន កសាងព្រះវិហារ ផ្តល់សម្ភារសិក្សាដល់សិស្សានុសិស្ស ផ្តល់អំណោយដល់ពលរដ្ឋខ្វះខាត និងចូលរួមឧបត្ថម្ភថវិកាដល់រាជរដ្ឋាភិបាលក្នុងការទប់ស្កាត់ជម្ងឺឆ្លងកូវីដ-១៩ ជាដើម។

លោកស្រី **ព្រហ្ម រដ្ឋា** បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ នៅសាកលវិទ្យាល័យក្នុងស្រុក និងបានបន្តការសិក្សានៅក្រៅប្រទេសផងដែរ។

**បណ្ឌិត ឥន យឿន**

**សមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យនៃគ្រឹះស្ថាន វ៉ាយ.អិល.ភី មីក្រូហិរញ្ញវត្ថុ ម.ក**



បណ្ឌិត **ឥន យឿន** ត្រូវបានម្ចាស់ភាគហ៊ុនធ្វើការតែងតាំងជាសមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យនៃគ្រឹះស្ថាន វ៉ាយ.អិល.ភី មីក្រូហិរញ្ញវត្ថុ ម.ក នៅថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ២០២៣។

មុនពេលចូលរួមជាសមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យនៅគ្រឹះស្ថាន វ៉ាយ.អិល.ភី លោកមានបទពិសោធន៍ការងាររយៈពេលជាង ២៧ឆ្នាំ តាំងពីឆ្នាំ១៩៩៦មក ដែលមានតួនាទីជាច្រើនដូចជា៖ ជាអ្នកនិពន្ធ និងយកព័ត៌មាននៅកាសែតនិសិត្ស ជាអតីតមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាគ្រូបង្រៀនវិជ្ជាជីវៈសាព័ត៌មាននៅអង្គការសិទ្ធិមនុស្ស ជាអគ្គនាយកវិទ្យុសម្លេងស្ត្រីកម្ពុជា ជាសាស្ត្រាចារ្យច្បាប់នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និង៨សាកលវិទ្យាល័យផ្សេងទៀតនៅរាជធានីភ្នំពេញ។

បណ្ឌិត **ឥន យឿន** បានបញ្ចប់ថ្នាក់បត្របរិញ្ញាបត្រនីតិសាស្ត្រ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច នៅឆ្នាំ១៩៩៩ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ នីតិសាស្ត្រ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច នៅឆ្នាំ២០០៦ និងបានបញ្ចប់ការសិក្សាថ្នាក់បណ្ឌិតនីតិសាស្ត្រ នៅរាជបណ្ឌិតសភាកម្ពុជាឆ្នាំ២០១៨។ ហើយនៅក្នុងចន្លោះឆ្នាំ១៩៩៦ ដល់ ២០០៧ លោកក៏បានទទួលសញ្ញាបត្រជំនាញទាំងក្នុង និងក្រៅប្រទេសផងដែរ មានដូចជា៖ សញ្ញាបត្រវិជ្ជាជីវៈច្បាប់ សញ្ញាបត្រស្ទាតកបត្រនីតិសាស្ត្រ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច វិញ្ញាបនបត្រវិជ្ជាជីវៈសារព័ត៌មាន និងកុំព្យូទ័រ នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ វិញ្ញាបនបត្រវិជ្ជាជីវៈភាសាអង់គ្លេស នៅសាធារណរដ្ឋឥណ្ឌា វិញ្ញាបនបត្រ E-Government នៅក្រសួងការបរទេសសិង្ហបុរី និងវិញ្ញាបនបត្រច្បាប់អន្តរជាតិ និងការចរចារអន្តរជាតិនៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

## ៤. ភាគទុនិក




| ល.រ | ម្ចាស់ភាគហ៊ុន | ភាគហ៊ុន | | |
|---|---|---|---|---|
| | | ចំនួនទឹកប្រាក់ | ចំនួនហ៊ុន | ភាគរយ(%) |
| ១ | លោកស្រី ម៉ៅ ម៉ាល័យ | ២.៤០០.០០០.០០០ រៀល | ៤០០ | ៤០% |
| ២ | លោក កែ សួនសុភា | ៩០.០០០.០០០ រៀល | ១៥០ | ១៥% |
| ៣ | លោកស្រី កែ សួនសុភី | ៩០.០០០.០០០ រៀល | ១៥០ | ១៥% |
| ៤ | លោកស្រី ព្រហ្ម រដ្ឋា | ៩០.០០០.០០០ រៀល | ១៥០ | ១៥% |
| ៥ | កញ្ញា ឈឿង វិធា | ៩០.០០០.០០០ រៀល | ១៥០ | ១៥% |
| | សរុប | ៦.០០០.០០០.០០០ រៀល | ១.០០០ | ១០០% |

## ៥. គណៈគ្រប់គ្រង



## លោក កែ សួនសុភា
## អគ្គនាយកនៃគ្រឹះស្ថាន វ៉ាយ.អិល.ភី មីក្រូហិរញ្ញវត្ថុ ម.ក



លោក **កែ សួនសុភា** ត្រូវបានតែងតាំងជា "**អគ្គនាយក**" របស់គ្រឹះស្ថាន វ៉ាយ.អិល.ភី មីក្រូហិរញ្ញវត្ថុ ម.ក និងបានទទួលស្គាល់ដោយធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២៣ ។ ក្នុងតួនាទីជា "**អគ្គនាយក**" លោកទទួលភារកិច្ចក្នុងការដឹកនាំ ចាត់ចែង គ្រប់គ្រង និងបង្កើតផែនការ (ធនធានមនុស្ស ផលិតផលទ្រព្យសកម្ម និងប្រាក់ចំណេញ) និងយុទ្ធសាស្រ្ត (រយៈពេលខ្លី មធ្យម និងវែង) ដើម្បីធ្វើយ៉ាងណាឱ្យប្រតិបត្តិការរបស់គ្រឹះស្ថាន ដំណើរការទៅដោយរលូន មានប្រសិទ្ធិភាពខ្ពស់ និងការពារបាននូវហានិភ័យផ្សេងៗ។

ក្រៅពីការងារនៅគ្រឹះស្ថាន វ៉ាយ.អិល.ភី លោក **កែ សួនសុភា** ក៏មានតួនាទីជាអនុប្រធានគណៈកម្មាធិការប្រតិបត្តិរបស់សមាគមមូលនិធិ វ៉ាយ.អិល.ភី និងជាស្ថាបនិកមួយរូបនៃមណ្ឌលកុមារកំព្រាវិសាខានៃក្តីសង្ឃឹមផងដែរ។

លោក **កែ សួនសុភា** បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែកទេសចរណ៍ នៅសាកលវិទ្យាល័យជាតិគ្រប់គ្រង នៅទីក្រុងភ្នំពេញ នៅឆ្នាំ២០០៨ និងបានបន្តការសិក្សានៅក្រៅប្រទេស មានដូចជាប្រទេសសិង្ហបុរី ជប៉ុន និងសហរដ្ឋអាមេរិក។

## លោក គុន រដ្ឋា
## អគ្គនាយករងនៃគ្រឹះស្ថាន វ៉ាយ.អិល.ភី មីក្រូហិរញ្ញវត្ថុ ម.ក



លោក **គុន រដ្ឋា** ជាអគ្គនាយករងនៃគ្រឹះស្ថាន វ៉ាយ.អិល.ភី មីក្រូហិរញ្ញវត្ថុ ម.ក។ មុនពេលក្លាយជាអគ្គនាយករងនៅគ្រឹះស្ថាន វ៉ាយ.អិល.ភី លោកធ្លាប់ធ្វើជាអ្នកគ្រប់គ្រងនៅក្រុមហ៊ុនជាច្រើន ដូចជា÷ ជាអគ្គនាយកនៅក្រុមហ៊ុន RHMS shop Plc និងជាអគ្គនាយកនៅក្រុមហ៊ុន Ly Hour Leasing Plc។ ទន្ទឹមនឹងនេះ លោកបានចំណាយពេលជាង ១៥ឆ្នាំ ធ្វើការជាមួយ ធនាគារ អេស៊ីលីដា ភីអិលស៊ី (ទាំងនៅប្រទេសកម្ពុជា និងឡាវ) ដោយកាន់តួនាទីជាច្រើនចាប់តាំងពីបុគ្គលិកធម្មតា រហូតដល់ថ្នាក់គ្រប់គ្រង ដូចជា៖ ជាភ្នាក់ងារឥណទាន ជាគណនេយ្យករ ជាសវនករផ្ទៃក្នុង ជាប្រធានផ្នែកសវនកម្មផ្ទៃក្នុង ជាប្រធានការិយាល័យសវនកម្មផ្ទៃក្នុង ជាប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង និងជាប្រធាននាយកដ្ឋានហិរញ្ញវត្ថុ នៃធនាគារ អេស៊ីលីដា ប្រចាំទេសឡាវ។

លោកបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកហិរញ្ញវត្ថុ និងធនាគារ ក្នុងឆ្នាំ២០១៥ ពីសាកលវិទ្យាល័យជាតិគ្រប់គ្រង នៅទីក្រុងភ្នំពេញ និងបានចូលរួមសិក្សាក្នុងកម្មវិធី Australian Institute of Company Directors Program នៅទីក្រុងស៊ីដនី ប្រទេសអូស្ត្រាលីផងដែរ។

## លោក ម៉ា សុតី
## ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងរដ្ឋបាលនៃគ្រឹះស្ថាន វ៉ាយ.អិល.ភី មីក្រូហិរញ្ញវត្ថុ ម.ក



លោក **ម៉ា សុតី** បានចូលបំពេញការងារជាមួយគ្រឹះស្ថាន វ៉ាយ.អិល.ភី មីក្រូហិរញ្ញវត្ថុ ម.ក ចាប់តាំងពីខែវិច្ឆិកា ឆ្នាំ២០២១ ក្នុងតួនាទីជាអនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងរដ្ឋបាល ហើយលោកត្រូវបានតែងតាំងជាប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងរដ្ឋបាលចាប់តាំងពីថ្ងៃទី ០១ ខែកក្កដា ឆ្នាំ ២០២៣។

មុនពេលចូលបម្រើការងារនៅគ្រឹះស្ថាន វ៉ាយ.អិល.ភី លោកមានបទពិសោធនក្នុងវិស័យមីក្រូហិរញ្ញវត្ថុ និងធនាគារអស់រយៈពេលជាង ១១ឆ្នាំ តាំងពីឆ្នាំ២០០៨ ដែលមានតួនាទីជាច្រើនដូចជា៖ គណនេយ្យករសាខា ភ្នាក់ងារឥណទាន គណនេយ្យករ និងជាប្រធានគណនេយ្យករការិយាល័យកណ្តាល នៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សីលានិធិ លីមីធីត និងជាប្រធានក្រុមប្រតិបត្តិការសាខានៅធនាគារប្រៃសណីយ៍កម្ពុជា ក.អ។

លោក **ម៉ា សុតី** បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែកគណនេយ្យ-ហិរញ្ញវត្ថុ នៅសកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច នៅខេត្តបន្ទាយមានជ័យ ។ លោកបានចូលរួមវគ្គបណ្តុះបណ្តាលការងារក្នុងវិស័យមីក្រូហិរញ្ញវត្ថុ និងធនាគារជាច្រើនវគ្គជាមួយសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា និងស្ថាប័នបណ្តុះបណ្តាល ផ្សេងៗទៀត។

## លោក សិន ឌីន
## ប្រធាននាយកដ្ឋានធនធានមនុស្សនៃគ្រឹះស្ថាន វ៉ាយ.អិល.ភី មីក្រូហិរញ្ញវត្ថុ ម.ក



លោក **សិន ឌីន** បានចាប់ផ្តើមចូលបម្រើការងារជាប្រធាននាយកដ្ឋានធនធានមនុស្ស ជាមួយគ្រឹះស្ថាន វ៉ាយ.អិល.ភី មីក្រូហិរញ្ញវត្ថុ ម.ក ចាប់ពីខែវិច្ឆិកា ឆ្នាំ២០២១។ លោកទទួលខុសត្រូវក្នុងការរៀបចំ បង្កើត និងត្រួតពិនិត្យគោលការណ៍នានានៃនាយកដ្ឋានធនធានមនុស្ស និងដឹកនាំអនុវត្តន៍យុទ្ធសាស្ត្រធនធានមនុស្ស គោលនយោបាយ និងនីតិវិធី ព្រមទាំងផ្តោតលើការប្រើប្រាស់ធនធានមនុស្សប្រកបដោយប្រសិទ្ធិភាព ក្នុងការសម្រេចបាននូវផែនការរំពឹងទុក ក្នុងបរិបទនៃការប្រកួតប្រជែង។

មុនចូលបម្រើការងារនៅ វ៉ាយ.អិល.ភី លោកធ្លាប់មានបទពិសោធន៍ការងារនៅតាមគ្រឹះស្ថាន និងស្ថាប័នមួយចំនួនដូចជា៖ ជាស្ថាបនិក និងជានាយកសាលាអន្តរជាតិប្រាយធ័រប្រ៊ីជ (BBiS) ប្រធានគណនេយ្យ-រដ្ឋបាល និងធនធានមនុស្សនៅមជ្ឈមណ្ឌលអូស្ត្រាលីសម្រាប់ការអភិវឌ្ឍកម្ពុជា ជាគ្រូបង្រៀនភាសាអង់គ្លេសនៅសាកលវិទ្យាល័យជាតិមានជ័យ និងនៅតាមបណ្តាគ្រឹះស្ថានអប់រំឯកជនមួយចំនួនទៀត។ ក្រៅពីនេះលោកក៏ធ្លាប់ធ្វើជាគ្រូបណ្តុះបណ្តាលផ្នែកអប់រំវិស័យទេសចរណ៍ និងបដិសណ្ឋារកិច្ច ប្រធានផ្នែកលក់នៃក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត Manulife (Cambodia) plc មន្ត្រីក្នុងកម្មវិធីស្វែងរកម្ចាស់ជំនួយជាមួយអង្គការ Good Neighbors International (Cambodia) និងជាអ្នកសម្របសម្រួលកម្មវិធីអប់រំយុវជនក្នុងសហគមន៍ជាមួយសមាគម KYA ផងដែរ។

លោក **សិន ឌីន** បានបញ្ចប់ថ្នាក់បរិញ្ញបត្រអប់រំ ផ្នែកបង្រៀនភាសាអង់គ្លេស នៅឆ្នាំ២០១២ ពីសាកលវិទ្យាល័យជាតិមានជ័យ (NMU) ខេត្តបន្ទាយមានជ័យ។ លោកក៏បានចូលរួមវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាជាច្រើន ដូចជា៖ យុទ្ធសាស្រ្តក្នុងការគ្រប់គ្រងធនធានមនុស្ស ការប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិកម្មដ៏មានប្រសិទ្ធភាព (LACMS & SICMS) របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ការអភិវឌ្ឍផែនការអាជីវកម្ម,ការសរសេរគម្រោងសំណើ វគ្គបណ្តុះបណ្តាលអ្នកគ្រប់គ្រងអាជីវកម្ម (MSME) ស្តង់ដារអាជីវកម្ម និងការជម្រុញទីផ្សារ និងការលក់ វគ្គបណ្តុះបណ្តាលគ្រូបង្គោលក្របខណ្ឌអាស៊ាន ITC ផ្នែកធានារ៉ាប់រងអាយុជីវិត និងវគ្គបណ្តុះបណ្តាលប្រព័ន្ធតេស្តភាសាអង់គ្លេសអន្តរជាតិ។

## លោក សែ វ៉ាន់ហៃ
## ប្រធាននាយកដ្ឋានព័ត៌មានវិទ្យានៃគ្រឹះស្ថាន វ៉ាយ.អិល.ភី មីក្រូហិរញ្ញវត្ថុ ម.ក



លោក **សែ វ៉ាន់ហៃ** បានចូលបម្រើការងារជាមួយគ្រឹះស្ថាន វ៉ាយ.អិល.ភី មីក្រូហិរញ្ញវត្ថុ ម.ក ក្នុងតួនាទីជាប្រធាននាយកដ្ឋានព័ត៌មានវិទ្យា ក្នុងខែវិច្ឆកា ឆ្នាំ២០២១។ ក្នុងតួនាទីជាប្រធាននាយកដ្ឋាន លោកទទួលខុសត្រូវលើការងារសំខាន់ៗដូចជា៖ តម្លើងប្រព័ន្ធស្នូលធនាគារ រៀបចំ និងបង្កើតគោលការណ៍ប្រតិបត្តិព័ត៌មានវិទ្យា រៀបចំបណ្តាញNetwork គ្រប់ការិយាល័យ ព្រមទាំងធ្វើការជ្រើសរើស និងហ្វឹកហ្វឺនបុគ្គលិកព័ត៌មានវិទ្យាក្នុងនាយកដ្ឋាន។ ទន្ទឹមនឹងនេះលោកក៏មានតួនាទីផ្សេងទៀតដូចជា៖ ប្រធានគណកម្មាធិការវាយតម្លៃគុណភាពសាងសង់អគារ និងប្រធានក្រុមគាំទ្រអាជីវកម្ម។

មុនពេលលោកចូលបម្រើការងារនៅគ្រឹះស្ថាន វ៉ាយ.អិល.ភី មីក្រូហិរញ្ញវត្ថុ ម.ក លោកធ្លាប់បម្រើការងារផ្នែកព័ត៌មានវិទ្យារយៈពេល ៨ឆ្នាំ ជាមួយក្រុមហ៊ុនបច្ចេកវិទ្យាមួយក្នុងខេត្តសៀមរាប ដែលធ្លាប់ដឹកនាំគម្រោងជាច្រើនទាក់ទងនឹងការគ្រប់គ្រងប្រព័ន្ធមជ្ឈមណ្ឌលទិន្នន័យ ការរៀបចំបណ្តាញនៅតាមស្ថាប័នមីក្រូហិរញ្ញវត្ថុ ក្រុមហ៊ុនធានារ៉ាប់រង សណ្ឋាគារ និងផ្សារទំនើប។

លោកបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ វិទ្យាសាស្រ្តព័ត៌មានវិទ្យា នៅឆ្នាំ២០១៤។ ក្នុងឆ្នាំ២០២១ លោកបានបញ្ចប់វគ្គបណ្តុះបណ្តាលពីទីផ្សារក្នុងវិស័យឌីជីថលជាមួយគម្រោង GIZ SIEM REAP DIGITAL MARKETING និងចូលរួមបណ្តុះបណ្តាលគម្រោង GIZ BATTAMBONG DIGITAL MARKETING។ នៅឆ្នាំ ២០២៣ លោកបានបញ្ចប់ការសិក្សាពីកម្មវិធី NSE1, NSE2, NSE3 ពីក្រុមហ៊ុន Fortinet។

### លោក សារិទ្ធ ទិចិត្រ
### មន្ត្រីសវនករជាន់ខ្ពស់នៃគ្រឹះស្ថាន វ៉ាយ.អិល.ភី មីក្រូហិរញ្ញវត្ថុ ម.ក



លោក **សារិទ្ធ ទិចិត្រ** បានចូលបម្រើការងារជាមួយគ្រឹះស្ថាន វ៉ាយ.អិល.ភី មីក្រូហិរញ្ញ ម.ក ក្នុងតួនាទីជា មន្ត្រីសវនករជាន់ខ្ពស់នៃនាយកដ្ឋានសវនកម្មផ្ទៃក្នុង។ មកដល់បច្ចុប្បន្ននេះ លោកមានបទពិសោធន៍ការងារក្នុងវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុ អស់រយៈពេលជាង ១១ឆ្នាំហើយ ដោយធ្លាប់បម្រើការងារជាមួយធនាគារអេស៊ីលីដា និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់។

លោក **សារិទ្ធ ទិចិត្រ** បានឆ្លងកាត់តួនាទីជាច្រើនមុនចូលបម្រើការងារជាមួយគ្រឹះស្ថាន វ៉ាយ.អិល.ភី មីក្រូហិរញ្ញវត្ថុ ម.ក ដូចជា៖ ភ្នាក់ងារឥណទាន សវនករផ្ទៃក្នុង សវនករភូមិភាគ និងសវនករផ្ទៃក្នុងជាន់ខ្ពស់នៃនាយកដ្ឋានសវនកម្មផ្ទៃក្នុង។ ទន្ទឹមនឹងនេះលោកបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលជាច្រើនដូចជា៖ វគ្គបណ្តុះបណ្តាលណែនាំសម្រាប់មន្ត្រីឥណទាន និងសវនករផ្ទៃក្នុងនៅធនាគារអេស៊ីលីដា និងវគ្គបណ្តុះបណ្តាលណែនាំសម្រាប់សវនករភូមិភាគនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់។

លោក **សារិទ្ធ ទិចិត្រ** បានបញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកអភិវឌ្ឍន៍សហគមន៍ នៃសាកលវិទ្យាល័យជាតិមានជ័យ និងកំពុងបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ នៃវិទ្យាស្ថានហិរញ្ញវត្ថុ និងគណនេយ្យ IFA ជំនាញសវនកម្ម និងពន្ធដារ។

### លោក មិន ផាន់ណារ៉ាត
### ប្រធាននាយកដ្ឋានគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាមនៃគ្រឹះស្ថាន វ៉ាយ.អិល.ភី មីក្រូហិរញ្ញវត្ថុ ម.ក



លោក **មិន ផាន់ណារ៉ាត** បានចូលបម្រើការងារជាមួយគ្រឹះស្ថាន វ៉ាយ.អិល.ភី មីក្រូហិរញ្ញវត្ថុ ម.ក ក្នុងតួនាទីជាប្រធាននាយកដ្ឋានគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម នៅខែវិច្ឆិកា ឆ្នាំ២០២២។ មុនចូលបម្រើការងារនៅគ្រឹះស្ថាន វ៉ាយ.អិល.ភី លោកមានបទពិសោធន៍រយៈពេល ៩ឆ្នាំ នៅក្នុងវិស័យគ្រឹះស្ថានហិរញ្ញវត្ថុ និងមិនមែនគ្រឹះស្ថានហិរញ្ញវត្ថុ ដោយធ្លាប់បម្រើការងារជាមួយធនាគារ ឌីជីប៊ី ម.ក បម្រើការនៅសាលាអន្តរជាតិញូវយ៉ក និងក្រុមហ៊ុនសេវាអ៊ីនធើណេត (AA Net) ក្នុងតួនាទីជាច្រើនដូចជា៖ ផ្នែកគិតលុយ មន្ត្រីគ្រប់គ្រងឃ្លាំង និងសន្និធិ ជាមន្ត្រីបម្រើសេវាអតិថិជន មន្ត្រីរដ្ឋបាលឥណទាន និងជាមន្ត្រីប្រតិបត្តិតាម។ លោក **មិន ផាន់ណារ៉ាត** បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែកគ្រប់គ្រង ក្នុងឆ្នាំ ២០១៩ នៅសាកលវិទ្យាល័យអាស៊ី អឺរ៉ុប នៅទីក្រុងភ្នំពេញ។ ទន្ទឹមនឹងនេះ លោកបានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម រៀបចំដោយវិទ្យាស្ថានហិរញ្ញវត្ថុ និងគណនេយ្យ សិក្ខាសាលាស្តីពីការប្រតិបត្តិតាម ច្បាប់ស្តីពីការងារ និងវគ្គបណ្តុះបណ្តាលស្តីពីការប្រតិបត្តិច្បាប់ប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ហើយបច្ចុប្បន្នលោកកំពុងសិក្សា វិញ្ញាបនបត្រកម្រិត១ "ផ្នែកប្រតិបត្តិតាម" រៀបចំដោយវិទ្យាស្ថានធនាគារ និងហិរញ្ញវត្ថុ (IBF)។

**លោក សាត់ វេង**

**ប្រធាននាយកដ្ឋានឥណទាននៃគ្រឹះស្ថាន វ៉ាយ.អិល.ភី មីក្រូហិរញ្ញវត្ថុ ម.ក**



លោក **សាត់ វេង** បានចូលបម្រើការងារជាមួយគ្រឹះស្ថាន វ៉ាយ.អិល.ភី មីក្រូហិរញ្ញវត្ថុ ម.ក ក្នុងតួនាទីជាប្រធាននាយកនាយកដ្ឋានឥណទាន។ មកដល់បច្ចុប្បន្ននេះ លោកមានបទពិសោធន៍ការងារ ក្នុងវិស័យមីក្រូហិរញ្ញវត្ថុ អស់រយៈពេលជាង ២៣ឆ្នាំ និងធ្លាប់បម្រើការងារជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុសីលានិធិ លីមីធីត គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមហានគរ និងធី&ហ្គូ ហ្វាយនែន ភីអិលស៊ី ដោយបានឆ្លងកាត់តួនាទីជាច្រើន ដូចជា៖ ភ្នាក់ងារឥណទាន ប្រធានភ្នាក់ងារឥណទាន ប្រធានសាខា ប្រធានតំបន់ ប្រធាននាយកដ្ឋានប្រតិបត្តិការជំនួយការអគ្គនាយក និងប្រធាននាយកដ្ឋានឥណទាន។

លោក **សាត់ វេង** បានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិត នៅសកលវិទ្យាល័យអាស៊ីអឺរ៉ុប ផ្នែកគ្រប់គ្រងពាណិជ្ជកម្ម ក្នុងឆ្នាំ២០២១។ ទន្ទឹមនឹងនេះ លោកក៏បានចូលវគ្គបណ្តុះបណ្តាលជាច្រើន ជាមួយសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា និងបានចូលរួមវគ្គបណ្តុះបណ្តាលការងារឥណទាន នៅប្រទេសហ្វីលីពីន ចំនួន ២លើក នៅវិទ្យាស្ថាន CMDI of CARD MRI, Philippine និងធនាគារ CARD BANK, Philippine ។

# ៦. រចនាសម្ព័ន្ធគ្រប់គ្រង



# III. និន្នាការនៃសេដ្ឋកិច្ចកម្ពុជា



នៅក្នុងឆ្នាំ២០២៣នេះ ក្រោយពីបានងើបឡើងវិញពីវិបត្តិកូវីដ-១៩ សេដ្ឋកិច្ចពិភពលោកនៅតែឆ្លងកាត់ឧបសគ្គជាបន្តបន្ទាប់ ហើយនៅតែបន្តប្រឈមនឹងការអូសបន្លាយដោយសារវិបត្តិភូមិសាស្ត្រនយោបាយនៃសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន និងសង្គ្រាមរវាងអ៊ីស្រាអែល-ហាម៉ាស់ បញ្ហាវិបត្តិអចលនទ្រព្យ ការរឹតបន្តឹងគោលនយោបាយរូបិយវត្ថុ និងការធ្លាក់ចុះនៃតម្រូវការក្នុងប្រទេសចិន។ តាមរបាយការណ៍របស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) បានធ្វើការព្យាករណ៍ថា កំណើនសេដ្ឋកិច្ចពិភពលោកកើនក្នុងអត្រា ៣% កំណើនសេដ្ឋកិច្ចប្រទេសអភិវឌ្ឍន៍កើនក្នុងអត្រា ១,៥% កំណើនសេដ្ឋកិច្ចប្រទេសកំពុងលូតលាស់ និងកំពុងអភិវឌ្ឍន៍កើនក្នុងអត្រា ៤% និងកំណើនសេដ្ឋកិច្ចអាស៊ានកើនក្នុងអត្រា ៤,៤%។

ការថយចុះនៃកំណើនសេដ្ឋកិច្ចពិភពលោក និងក្នុងតំបន់ក៏ជាបញ្ហាមួយដែលបានដាក់សម្ពាធមកដល់សេដ្ឋកិច្ចកម្ពុជាផងដែរ ជាពិសេសការនាំចេញនូវផលិតផលកាត់ដេរ កំណើនលើវិស័យអចលនទ្រព្យ និងសំណង់។ ទោះជាយ៉ាងណា ការងើបឡើងមកវិញនៃវិស័យទេសចរណ៍ ការកើនឡើងក្នុងការនាំចេញផលិតផលមិនមែនកាត់ដេរ និងកំណើនតម្រូវការក្នុងស្រុក ក៏បានរួមចំណែកគាំទ្រសេដ្ឋកិច្ចកម្ពុជាឱ្យមានការកើនឡើងក្នុងអត្រា ០,២% នេះបើធៀបជាមួយឆ្នាំ២០២២។

យោងតាមរបាយការណ៍ស្ថានភាពសេដ្ឋកិច្ចកម្ពុជារបស់ធនាគារពិភពលោក សេដ្ឋកិច្ចកម្ពុជានឹងមានកំណើនក្នុងអត្រា ៥,៨% ក្នុងឆ្នាំ២០២៤ ដោយសំអាងលើវិស័យចំនួន៣ រួមមាន វិស័យឧស្សាហកម្ម សេវាកម្ម និងកសិកម្ម នឹងមានការងើបឡើងវិញក្នុងឆ្នាំ២០២៤នេះ។ ទន្ទឹមនឹងនោះ វិស័យឧស្សាហកម្មត្រូវបានព្យាករណ៍ថា នឹងបន្តកើនឡើងក្នុងរង្វង់ ៨,៥% ដោយសារការរំពឹងទុកនៃការងើបឡើងវិញនៃអនុវិស័យកាត់ដេរ និងកម្មន្តសាលមិនមែនកាត់ដេរ។ មួយវិញទៀត វិស័យសេវាកម្មត្រូវបានព្យាករណ៍ថានឹងបន្តល្អប្រសើរក្នុងអត្រាកំណើន ៦,៩% ដោយសារការងើបឡើងនៃសកម្មភាពសេដ្ឋកិច្ចក្នុងស្រុក ជាពិសេសអនុវិស័យសណ្ឋាគារ ភោជនីយដ្ឋាន និងសេវាកម្មគាំទ្រផ្សេងទៀត ដូចជាអនុវិស័យលក់ដុំ-រាយ និងអនុវិស័យដឹកជញ្ជូន និងគមនាគមន៍។ ជាមួយគ្នានេះដែរ វិស័យកសិកម្មក៏រំពឹងថានឹងមានកំណើនក្នុងរង្វង់ ១,១% ក្នុងឆ្នាំនេះ ដោយសារភាពប្រសើរឡើងនៃអនុវិស័យដំណាំ និងការងើបឡើងនៃអនុវិស័យនេសាទ ខណៈដែលអនុវិស័យចិញ្ចឹមសត្វនៅបន្តមានស្ថិរភាព។

## ស្ថានភាពប្រព័ន្ធធនាគារនៅកម្ពុជា



ចំពោះស្ថានភាពប្រព័ន្ធគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុនៅតែបន្តមានសុខភាពល្អ ព្រមទាំងបានរួមចំណែកគាំទ្រការងើបឡើងវិញនៃសកម្មភាពសេដ្ឋកិច្ច ទោះប្រឈមនឹងវិបត្តិដែលបានអូសបន្លាយកន្លងមកក៏ដោយ។ ដោយស្ថានភាពដើមទុនរបស់ប្រព័ន្ធធនាគារ និងសន្ទនីយភាពមានភាពរឹងមាំ ដោយអនុបាតសោធនភាពនៅមានកម្រិតខ្ពស់ដល់ ២២,៧% សម្រាប់ធនាគារ និង ២៥,៤% សម្រាប់គ្រឹះស្ថានហិរញ្ញវត្ថុ ខ្ពស់ជាងកម្រិតអប្បបរមាដែលកំណត់ដោយបទប្បញ្ញត្តិ (១៥%) ហើយអនុបាតគ្របខណ្ឌសន្ទនីយភាពមានអត្រា ១៦៧,៦% សម្រាប់ធនាគារពាណិជ្ជ និង ៣៣៣,៣% សម្រាប់គ្រឹះស្ថានមីក្រូទទួលប្រាក់បញ្ញើ ខ្ពស់ជាងកម្រិតអប្បបរមាកំណត់ដោយបទប្បញ្ញត្តិ (១០០%) តាមលទ្ធផលនៃការត្រួតពិនិត្យនេះ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុបង្ហាញភាពធន់នៃប្រព័ន្ធធនាគារពីការប៉ះទង្គិចនានា។

នៅចុងឆ្នាំ២០២៣ ទ្រព្យសកម្មរបស់ឧស្សាហកម្មហិរញ្ញវត្ថុសរុបបានកើនឡើង ៨,៦% (៨៤,៣ ប៊ីលានដុល្លារអាមេរិក)។ សម្ពាធឥណទានសរុបមានកំណើន ៤,៨% (៥៧,៦ ប៊ីលានដុល្លារអាមេរិក) សមតុល្យប្រាក់បញ្ញើសន្សំរបស់អតិថិជនសរុបកើនឡើង ១៣,១% (៤៧,៩ ប៊ីលានដុល្លារអាមេរិក) និងចំពោះអនុបាតឥណទានមិនដំណើរការបានបន្តកើនឡើងដល់ ៥,៤% សម្រាប់វិស័យធនាគារ និង ៦,៧% សម្រាប់វិស័យមីក្រូហិរញ្ញវត្ថុ ដោយសារការបញ្ចប់វិធានការការរៀបចំឥណទានឡើងវិញ និងការថមថយកំណើនឥណទាន។

# IV. ផលិតផល និងសេវាកម្ម

## ១. ប្រភេទផលិតផល

គ្រឹះស្ថាន វ៉ាយ.អិល.ភី មីក្រូហិរញ្ញវត្ថុ ម.ក បានបង្កើតនូវផលិតផល និងរបៀបនៃការបង់ប្រាក់ជាច្រើន ដើម្បីបម្រើជូនអតិថិជន ដោយមានភាពបត់បែន និងងាយស្រួលអោយស្របទៅនឹងតំរូវការអតិថិជន ដែលស្ថិតក្នុងតំបន់ប្រតិបត្តិការជាក់ស្តែង មានដូចជា៖




- ❖ ឥណទានក្រុម
- ❖ ឥណទានខ្នាតតូចបំផុត
- ❖ ឥណទានខ្នាតតូច
- ❖ ឥណទានខ្នាតមធ្យម
- ❖ ឥណទានផ្ទាល់ខ្លួន
- ❖ ឥណទានបុគ្គលិក
- ❖ ឥណទានរហ័ស



**សម្រាប់របៀបបង់ប្រាក់ គ្រឹះស្ថានមានច្រើនជម្រើសសម្រាប់ផ្តល់ជូនអតិថិជន ដើម្បីអោយស្របទៅនឹងលំហូរសាច់ប្រាក់ និងប្រភេទមុខរបរ ដូចជា៖**

- ❖ បង់ការប្រាក់ប្រចាំខែ និងប្រាក់ដើមសរុបនៅចុងវគ្គ
- ❖ បង់ការប្រាក់ប្រចាំខែ និងប្រាក់ដើមមួយផ្នែក
- ❖ បង់ការប្រាក់ និងប្រាក់ដើមប្រចាំខែ
- ❖ បង់ការប្រាក់ និងប្រាក់ដើមប្រចាំខែថេរ
- ❖ បង់ការប្រាក់ប្រចាំខែ និងបង់ប្រាក់ដើមតាមការចចារ

## ២. ផលបត្រឥណទាន

ក្នុងឆ្នាំ២០២៣ គ្រឹះស្ថានបានផ្តល់ឥណទានដល់អតិថិជនសរុបចំនន្ទន ៣៩៥នាក់ ដែលមានទឹកប្រាក់សរុបស្មើ ៣.០៩៥.៣៨៩ ដុល្លារ។ គិតត្រឹមចុងឆ្នាំ២០២៣ គ្រឹះស្ថានមានអតិថិនជនសកម្មសរុបចំនួន ៨០៩នាក់ ជាមួយនឹងផលបត្រឥណទានសរុបចំនួន ៦.៣៨១.៤៣៦ ដុល្លារ ដែលមានលម្អិតដូចខាងក្រោម៖

## ❖ ផលបត្រឥណទានតាមវិស័យ

| ល.រ | វិស័យ | ចំនួនអតិថិជន | សមតុល្យឥណទាន |
|---|---|---|---|
| ១ | កសិកម្ម | ២១៦ នាក់ | ១.៥២៤.០៣១ ដុល្លារ |
| ២ | ជំនួញ និងពាណិជ្ជកម្ម | ១៦១ នាក់ | ១.៥២០.៤០៤ ដុល្លារ |
| ៣ | សេវាកម្ម | ១២១ នាក់ | ១.០១៥.០២៩ ដុល្លារ |
| ៤ | ដឹកជញ្ជូន | ៧ នាក់ | ៧០.១២៤ ដុល្លារ |
| ៥ | សាងសង់ | ៦៦ នាក់ | ៥១៣.៧០១ ដុល្លារ |
| ៦ | ប្រើប្រាស់ផ្ទាល់ខ្លួន | ២៣៦ នាក់ | ១.៧៣០.១៤៨ ដុល្លារ |
| ៧ | ផ្សេងៗ | ២ នាក់ | ៧.៩៩៩ ដុល្លារ |
| | **សរុប** | **៨០៩ នាក់** | **៦.៣៨១.៤៣៦ ដុល្លារ** |



### ❖ ផលបត្រឥណទានតាមប្រភេទផលិតផល

| ល.រ | ប្រភេទផលិតផល | ចំនួនអតិថិជន | សមតុល្យឥណទាន |
|---|---|---|---|
| ១ | ឥណទានក្រុម | ០ នាក់ | ០ ដុល្លារ |
| ២ | ឥណទានខ្នាតតូចបំផុត | ២៥ នាក់ | ១៣.៧៦០ ដុល្លារ |
| ៣ | ឥណទានខ្នាតតូច | ៤២២ នាក់ | ១.៤៦១.២៦០ ដុល្លារ |
| ៤ | ឥណទានខ្នាតមធ្យម | ១៧៨ នាក់ | ៣.៦៩៦.៤៩៩ ដុល្លារ |
| ៥ | ឥណទានផ្ទាល់ខ្លួន | ១៧៩ នាក់ | ៩៨៤.៩១៧ ដុល្លារ |
| ៦ | ឥណទានបុគ្គលិក | ០ នាក់ | ០ ដុល្លារ |
| ៧ | ឥណទានរហ័ស | ៥ នាក់ | ២២៥.០០០ ដុល្លារ |
| | **សរុប** | **៨០៩ នាក់** | **៦.៣៨១.៤៣៦ ដុល្លារ** |



## ៣. ចំណាប់អារម្មណ៍អតិថិជន



### ឈ្មោះ ភីម ក្លូ (ឥណទានកសិកម្ម)

ក្រោយពីទទួលប្រាក់កម្ចីពីគ្រឹះស្ថានវ៉ាយ.អិល.ភី មីក្រូហិរញ្ញវត្ថុ ម.ក ខ្ញុំអាចពង្រីកមុខរបរកសិកម្មរបស់ខ្ញុំបានយ៉ាងច្រើន និងអាចឱ្យខ្ញុំទទួលបានចំណូលបន្ថែមទៀត ដើម្បីសម្រួលជីវភាពក្នុងគ្រួសារ។ បច្ចុប្បន្នខ្ញុំមានជីវភាពធូរធាច្រើនជាងមុន ក្រោយពីទទួលបានប្រាក់កម្ចី និងមានលទ្ធភាពអោយកូនបានរៀនសូត្រគ្រប់ៗគ្នា។

### ឈ្មោះ ញ៉ូន ល្វៃ (ឥណទានអាជីវកម្ម)

នាងខ្ញុំបានស្នើសុំកម្ចីពីគ្រឹះស្ថាន វ៉ាយ.អិល.ភី មីក្រូហិរញ្ញវត្ថុ ម.ក ដើម្បីជាដើមទុនក្នុងសិប្បកម្មទឹកសុទ្ធរបស់នាងខ្ញុំ។ បច្ចុប្បន្នសិប្បកម្មទឹកសុទ្ធរបស់នាងខ្ញុំអាចមានលទ្ធភាពផលិត ដើម្បីផ្គត់ផ្គង់ទៅទីផ្សារបានច្រើនជាងមុន ហើយអាចដំណើរការបានយ៉ាងរលូនជាងអ្វីដែលខ្ញុំរំពឹងទុក ធ្វើឱ្យខ្ញុំអាចរកចំណូលបានច្រើនជាងមុន និងទំហំសិប្បកម្មកាន់តែធំជាងមុន។ រហូតមកដល់ពេលនេះ វាធ្វើអោយជីវភាពរបស់នាងខ្ញុំកាន់តែប្រសើរឡើង។





### ឈ្មោះ ទូច ធារី (ឥណទានប្រើប្រាស់ផ្ទាល់ខ្លួន)

នាងខ្ញុំបានស្នើសុំកម្ចីប្រើប្រាស់ផ្ទាល់ខ្លួនពីគ្រឹះស្ថាន វ៉ាយ.អិល.ភី មីក្រូហិរញ្ញវត្ថុ ម.ក ដើម្បីសាងសង់គេហដ្ឋាន។ បច្ចុប្បន្ន ផ្ទះរបស់នាងបានសាងសង់រួចរាល់មួយរយភាគរយ ក្រោយពីបានប្រើប្រាស់ប្រាក់កម្ចីពីគ្រឹះស្ថាន វ៉ាយ.អិល.ភី មីក្រូហិរញ្ញវត្ថុ ម.ក។ នាងខ្ញុំមានផ្ទះរស់នៅសមរម្យ គ្រួសាររីករាយ មានសុភមង្គល វាបានធ្វើអោយគ្រួសាររបស់នាងខ្ញុំមានភាពរីកចម្រើន និងអាចប្រកបការងារបានយ៉ាងល្អប្រសើរ។

### ឈ្មោះ ញ៉ក់ វិនយ៉ា (ឥណទានមន្ត្រីរាជការ)

នាងខ្ញុំជាគ្រូបង្រៀនបានស្នើសុំប្រាក់កម្ចីពីគ្រឹះស្ថាន វ៉ាយ.អិល.ភី មីក្រូហិរញ្ញវត្ថុ ម.ក ដើម្បីយកទៅទិញសម្ភារប្រើប្រាស់ និងមធ្យោបាយធ្វើដំណើរ(ម៉ូតូ)។ បច្ចុប្បន្ន គ្រួសាររបស់នាងខ្ញុំមានសម្ភារប្រើប្រាស់គ្រប់គ្រាន់ ហើយមានមធ្យោបាយធ្វើដំណើរងាយស្រួល ដើម្បីទៅបំពេញការងារ និងបំពេញកិច្ចការផ្សេងៗ ។



# V. គណៈកម្មាធិការគ្រប់គ្រងគ្រឹះស្ថាន

## ក. កម្រិតក្រុមប្រឹក្សាភិបាល

### ១. គណៈកម្មាធិការក្រុមប្រឹក្សាភិបាល

**សមាសភាព ៖**

| | |
|---|---|
| ❖ លោកជំទាវ ម៉ៅ ម៉ាលច័យ | ប្រធាន |
| ❖ លោក កែ សួនសុភា | អភិបាល |
| ❖ លោកស្រី កែ សួនសុភី | អភិបាល |
| ❖ លោកស្រី ព្រហ្ម រដ្ឋា | អភិបាល |
| ❖ បណ្ឌិត ឥន យឿន | អភិបាលឯករាជ្យ |

**តួនាទី ៖**

- កំណត់យុទ្ធសាស្ត្រ គោលដៅអាជីវកម្មរបស់គ្រឹះស្ថាន។
- ធ្វើការពិនិត្យលើផែនការប្រចាំឆ្នាំ និងយុទ្ធសាស្ត្រអាជីវកម្មរបស់គ្រឹះស្ថាន។
- អនុម័តលើការជ្រើសរើស ការតែងតាំង ការបញ្ចប់មុខងារអគ្គនាយករបស់គ្រឹះស្ថាន និងការអនុម័តក្របខ័ណ្ឌនៃប្រាក់ឈ្នួលសម្រាប់នាយក ប្រាក់ឧបត្ថម្ភ និងអត្ថប្រយោជន៍តាមប្រភេទ (ក្រុមប្រឹក្សា និងគណៈកម្មាធិការទាំងអស់)។
- ពិនិត្យ និងអនុម័តគោលនយោបាយ សម្រាប់អនុវត្តទូទាំងគ្រឹះស្ថាន។
- បង្កើតឱ្យមានប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដើម្បីវាយតម្លៃ និងតាមដានទៅលើការអនុវត្តរបស់គ្រឹះស្ថាន ដើម្បីធានាថាហានិភ័យទាំងអស់គ្រប់គ្រង។

**ការប្រជុំ ៖** នៅក្នុងឆ្នាំ២០២៣ គណៈកម្មាធិការក្រុមប្រឹក្សាភិបាលបានធ្វើការប្រជុំចំនួន ២ដង (ដោយផ្ទាល់មុខ) ដែលធ្វើឡើងថ្ងៃទី ២៩ ខែកញ្ញា ឆ្នាំ២០២៣ និងថ្ងៃទី ២០ ខែធ្នូ ឆ្នាំ២០២៣ ដើម្បីធ្វើការពិនិត្យពិភាក្សា និងសម្រេចការងារមួយចំនួនខាងក្រោម៖

- ធ្វើការតាមដានផែនការសកម្មភាពដែលបានដាក់ចេញ។
- ធ្វើការពិនិត្យលើរបាយការណ៍អំពីវឌ្ឍនភាពប្រចាំខែរបស់គ្រឹះស្ថាន។
- ពិនិត្យ និងជ្រើសរើសក្រុមហ៊ុនសវនកម្មខាងក្រៅ សម្រាប់ឆ្នាំ២០២៣។
- ពិនិត្យ និងសម្រេចផែនការអាជីវកម្មឆ្នាំ២០២៤។
- ពិនិត្យ និងសម្រេចលើរបាយការណ៍សវនកម្មខាងក្រៅឆ្នាំ២០២២។
- ពិនិត្យ និងកែសម្រួលលើលក្ខន្តិកៈ ដើម្បីឱ្យស្របតាមសកម្មភាពអាជីវកម្ម។
- ពិនិត្យ និងអនុម័តលើការធ្វើវិសោធនកម្ម លើគោលការណ៍ហិរញ្ញវត្ថុ គោលការណ៍ឥណទាន និងគោលការណ៍ធនធានមនុស្ស។

## ២. គណៈកម្មាធិការគ្រប់គ្រងហានិភ័យ

**សមាសភាព ៖**

| | |
|---|---|
| ❖ លោក ឥន យឿន | ប្រធាន |
| ❖ លោកស្រី ព្រហ្ម រដ្ឋា | សមាជិក |
| ❖ លោកអគ្គនាយក | សមាជិក |
| ❖ លោកអគ្គនាយករង | សមាជិក |
| ❖ ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងរដ្ឋបាល | សមាជិក |
| ❖ ប្រធាននាយកដ្ឋានគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម | លេខាធិការ |

**តួនាទី ៖**

- ជួយក្រុមប្រឹក្សាភិបាលក្នុងការកែប្រែយុទ្ធសាស្ត្រ បេសកម្មឱ្យទៅជាកម្រិតមួយដែលអាចទទួលយកបាន សមស្រប និងកម្រិតហានិភ័យទាំងអស់ដែលគ្រឹះស្ថានប្រឈម ចំពោះវិសាលភាពនៃការសម្របសម្រួលត្រូវបានរាប់បញ្ចូលដោយមិនមានការកំណត់ទំហំ ដូចជាហានិភ័យប្រតិបត្តិការ ហានិភ័យឥណទាន ហានិភ័យសាច់ប្រាក់ងាយស្រួល ហានិភ័យប្រតិបត្តិតាម ហានិភ័យសេដ្ឋកិច្ច និងទីផ្សារ។
- ធានាឱ្យមានការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាពលើមុខងារ គ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម ក៏ដូចជាយុទ្ធសាស្ត្រ នីតិវិធី និងវិធានការត្រួតពិនិត្យដែលសមស្របដោយឯករាជ្យលើគ្រប់សកម្មភាព និងប្រតិបត្តិការរបស់គ្រឹស្ថាន វ៉ាយ.អិល.ភី។
- ពិនិត្យ និងផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សាភិបាល ដើម្បីអនុម័តលើក្របខណ្ឌគ្រប់គ្រងហានិភ័យ ក្របខណ្ឌអភិបាលកិច្ច រួមទាំងភាពសមស្របលើប្រសិទ្ធភាព ដោយឯករាជ្យភាពនៃការគ្រប់គ្រងហានិភ័យ។
- ពិនិត្យ និងផ្តល់ជាអនុសាសន៍ដល់ក្រុមប្រឹក្សាភិបាល ដើម្បីធ្វើការអនុម័តលើគោលនយោបាយគ្រប់គ្រងហា និភ័យ របស់គ្រឹះស្ថាន ដូចជាការកំណត់អត្តសញ្ញាណហានិភ័យ ការវាយតម្លៃលើហានិភ័យ ការតាមដានលើហានិភ័យ និងការរាយការណ៍អំពីហានិភ័យសំខាន់ៗ ដែលអាចកើតឡើង និងធ្វើអោយមានផលពិបាកលើដំណើរការប្រតិបត្តិការរបស់គ្រឹះស្ថាន វ៉ាយ.អិល.ភី។
- ត្រួតពិនិត្យការអនុវត្តគោលនយោបាយគ្រប់គ្រង់ហានិភ័យ និងការប្រតិបត្តិតាមវិធានច្បាប់ និងបទប្បញ្ញត្តិនីមួយៗ។
- ធ្វើការណែនាំដល់ការគ្រប់គ្រងប្រតិបត្តិក្នុងការអនុវត្តតាមក្របខណ្ឌគ្រប់គ្រងហានិភ័យ ធ្វើការកំណត់តួនាទី និងការទទួលខុសត្រូវឱ្យបានច្បាស់លាស់។

**ការប្រជុំ ៖** ក្នុងឆ្នាំ២០២៣ គណៈកម្មាធិការបានធ្វើការត្រួតពិនិត្យ លើដំណើរការងារសំខាន់ៗ មានដូចជា៖

- បានត្រួតពិនិត្យ និងផ្តល់ជាអនុសាសន៍ដល់ប្រធានក្រុមប្រឹក្សាភិបាលសម្រាប់ការអនុម័តចុងក្រោយលើរបាយការណ៍សវនកម្មខាងក្រៅសម្រាប់ឆ្នាំ២០២២។
- បានត្រួតពិនិត្យ និងផ្តល់អនុសាសន៍លើគោលការណ៍គ្រប់គ្រងហានិភ័យ ការគ្រប់គ្រងការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។

- ពិនិត្យ និងតាមដានលើរបាយការណ៍គ្រប់គ្រងហានិភ័យ និងរបាយការប្រតិបត្តិតាមប្រចាំខែ។
- ពិនិត្យតាមដានលើរបាយការណ៍គ្រប់គ្រងហានិភ័យឥណទានប្រចាំខែ។
- ពិនិត្យ វិភាគលើផលប៉ះពាល់នៃសេណារីយ៉ូហានិភ័យ ដែលអាចកើតឡើងលើតារាងតុល្យការ របាយការណ៍ចំណេញ-ខាត និងអនុបាតប្រុងប្រយ័ត្ន ដែលបានកំណត់ដោយធនាគារជាតិនៃកម្ពុជា។
- បានពិនិត្យលើរបាយការណ៍ប្រតិបត្តិតាម និងបានទទួលរបាយការណ៍វិភាគអំពីប្រភេទប្រតិបត្តិការដែលគួរឱ្យសង្ស័យក្នុងរង្វង់គ្រឹះស្ថាន។

## ៣. គណៈកម្មាធិការសវនកម្ម

**សមាសភាព ៖**

| | |
|---|---|
| ❖ លោក ឥន យឿន | ប្រធាន |
| ❖ លោកស្រី កែ សួនសុភី | សមាជិក |
| ❖ លោក កែ សួនសុភា | សមាជិក |
| ❖ លោក កុន រដ្ឋា | សមាជិក |
| ❖ ប្រធាននាយកដ្ឋានឥណទាន | សមាជិក |
| ❖ ប្រធាននាយកដ្ឋានសវនករផ្ទៃក្នុង | លេខាធិការ |

**តួនាទី ៖**

- គណៈកម្មាធិការសវនកម្ម ត្រូវបានបង្កើតឡើងដោយក្រុមប្រឹក្សាភិបាលនៃគ្រឹះស្ថាន វ៉ាយ.អិល.ភី មីក្រូហិរញ្ញវត្ថុ ម.ក ដើម្បីតាមដាន និងត្រួតពិនិត្យភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុ ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុផ្ទៃក្នុង សវនកម្មផ្ទៃក្នុង និងសេវាកម្ម ដែលផ្តល់ដោយសវនករខាងក្រៅ។
- ពិនិត្យឡើងវិញនូវកម្មវិធីសវនកម្មផ្ទៃក្នុង ដើម្បីធានានូវការសម្របសម្រួលរវាងសវនករផ្ទៃក្នុង និងឯករាជ្យ ហើយធានាថាមុខងាររបស់សវនកម្មផ្ទៃក្នុងមានលក្ខណ:គ្រប់គ្រាន់ និងមានគោលជំហរត្រឹមត្រូវនៅក្នុង គ្រឹះស្ថាន វ៉ាយ.អិល.ភី មីក្រូហិរញ្ញវត្ថុ ម.ក ហើយត្រូវបានត្រួតពិនិត្យ និងតាមដាននូវប្រសិទ្ធភាពនៃមុខងារ របស់សវនកម្មផ្ទៃក្នុង។
- ត្រូវធានាថាព័ត៌មាន ដែលបានផ្តល់ជូនដល់សាធារណជន និងធនាគារជាតិនៃកម្ពុជា មានភាពច្បាស់លាស់ ត្រឹមត្រូវ និងអាចទុកចិត្តបាន។
- ធានាថាសវនករផ្ទៃក្នុងធ្វើសវនកម្មជាទៀងទាត់ នូវវិធីសាស្ត្រគណនេយ្យកត់ត្រា និងរបាយការណ៍ហិរញ្ញវត្ថុ ដើម្បីឆ្លើយតបនឹងការរំពឹងទុកនៃបទប្បញ្ញត្តិ និងក្រុមប្រឹក្សាភិបាល។
- វាយតម្លៃ ត្រួតពិនិត្យ និងអនុម័ត ទៅលើគោលនយោបាយសវនកម្មផ្ទៃក្នុង នីតិវិធី និងផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ ជាពិសេសប្រព័ន្ធសម្រាប់វាស់តាមដាន ត្រួតពិនិត្យ និងគ្រប់គ្រងហានិភ័យមានភាពស៊ីសង្វាក់គ្នា និងផ្តល់អនុសាសន៍នូវចំណុចខ្វះខាត។
- ពិនិត្យ ផ្តល់យោបល់ និងវាយតម្លៃលើលក្ខណ:សម្បត្តិ និងឯករាជ្យភាពរបស់ក្រុមហ៊ុនគណនេយ្យសាធារណ:ដែលបានចុះបញ្ជី (សវនករឯករាជ្យខាងក្រៅ) ដែលគ្រឹះស្ថា វ៉ាយ.អិល.ភី ធ្វើការជ្រើសរើសក្នុងការធ្វើ សវនកម្មប្រចាំឆ្នាំ។

- ជួយដល់ក្រុមប្រឹក្សាភិបាល ក្នុងការត្រួតពិនិត្យលើការអនុវត្តស្តីពីគោលនយោបាយគណនេយ្យ និងការរៀបចំរបាយការណ៍ឱ្យបានត្រឹមត្រូវ គ្រប់គ្រាន់ និងធានាឱ្យបាននូវប្រសិទ្ធភាពនៃការត្រួតពិនិត្យផ្ទៃក្នុង។
- ត្រួតពិនិត្យលើការប្រតិបត្តិតាម គោលការណ៍នីតិវិធី បទប្បញ្ញត្តិច្បាប់ជាធរមាន។

**ការប្រជុំ ៖** ឆ្នាំ២០២៣គណៈកម្មាធិការបានធ្វើការត្រួតពិនិត្យ លើដំណើរការការងារសំខាន់ៗ មានដូចជា៖

- បានត្រួតពិនិត្យ អនុម័ត និងស្នើក្រុមប្រឹក្សាភិបាលសម្រាប់ការអនុម័តចុងក្រោយលើរបាយការណ៍សវនកម្មហិរញ្ញវត្ថុឆ្នាំ២០២២។
- បានត្រួតពិនិត្យ និងអនុម័តរបាយការណ៍ត្រួតពិនិត្យផ្ទៃក្នុងប្រចាំឆ្នាំ២០២២ ដើម្បីដាក់ជូនធនាគារជាតិនៃកម្ពុជា។
- បានត្រួតពិនិត្យរបាយការណ៍សវនកម្មផ្ទៃក្នុង និងការវិភាគនិន្នាការ ឬហេតុការណ៍នានា។
- បានត្រួតពិនិត្យ និងអនុម័តលើផែនការសវនកម្មផ្ទៃក្នុងសម្រាប់ឆ្នាំ២០២៤។
- បានពិភាក្សា និងអនុម័តជ្រើសរើសក្រុមហ៊ុនសវនកម្មខាងក្រៅ សម្រាប់ប្រចាំឆ្នាំ២០២៣។
- បានត្រួតពិនិត្យប្រចាំឆ្នាំនូវគោលការណ៍ផ្សេងៗ គោលការណ៍សវនកម្ម គោលការណ៍ត្រួតពិនិត្យផ្ទៃក្នុង និងគោលការណ៍ណែនាំទូទៅ។

## ខ. កម្រិតគណៈគ្រប់គ្រង

### ១. គណៈកម្មាធិការប្រតិបត្តិ

**សមាសភាព ៖**

| | |
|---|---|
| ❖ លោក អគ្គនាយក | ប្រធាន |
| ❖ លោក អគ្គនាយករង | សមាជិក |
| ❖ ប្រធាននាយកដ្ឋានឥណទាន | សមាជិក |
| ❖ ប្រធាននាយកដ្ឋានគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម | សមាជិក |
| ❖ ប្រធាននាយកដ្ឋានព័ត៌មានវិទ្យា | សមាជិក |
| ❖ ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងរដ្ឋបាល | សមាជិក |
| ❖ ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង | សមាជិក |
| ❖ ប្រធាននាយកដ្ឋានធនធានមនុស្ស | សមាជិក និងលេខាកត់ត្រា |

**តួនាទី ៖**

- អនុម័តលើបញ្ហាធុរកិច្ចសំខាន់ៗ ស្របតាមយុទ្ធសាស្ត្រដែលបានអនុម័ត និងក្នុងសមត្ថកិច្ចរបស់ខ្លួន ដែលចាត់តាំងដោយក្រុមប្រឹក្សាភិបាល។
- ពិនិត្យលើគោលនយោបាយធនធានមនុស្ស និងក្របខណ្ឌការងារគ្រឹះស្ថាន។
- ធ្វើការពិនិត្យ និងធ្វើសំណើទៅក្រុមប្រឹក្សាភិបាល ដើម្បីដាក់ឱ្យដំណើរការផលិតផល និងសេវាកម្មថ្មីៗ។

- ពិនិត្យ និងតាមដានការអនុវត្តហិរញ្ញវត្ថុរបស់អាជីវកម្ម និងស្នើវិធានការកែតម្រូវតាមតម្រូវការ ដើម្បីឱ្យស្របតាមគោលដៅដែលកំណត់។
- ពិនិត្យ និងតាមដានការអនុវត្តឥណទាន និងផលបត្រឥណទានហើយស្នើឱ្យមានសកម្មភាពកែតម្រូវតាមតម្រូវការ ដើម្បីឱ្យស្របតាមគោលបំណងដែលបានកំណត់។
- ពិនិត្យ និងតាមដានវឌ្ឍនភាពលើផែនការសកម្មភាព ដែលមានផលប៉ះពាល់យ៉ាងសំខាន់លើដំណើរការហិរញ្ញវត្ថុ និង/ឬប្រសិទ្ធភាពប្រតិបត្តិការរបស់គ្រឹះស្ថាន និងចាត់វិធានការកែតម្រូវ ដើម្បីធានាថាផែនការ សម្រេចបានតាមគោលបំណងដែលបានកំណត់។
- ពិនិត្យ និងតាមដានហានិភ័យដែលកំពុងកើតមាននៅក្នុងទីផ្សារ ការផ្លាស់ប្តូរនាពេលខាងមុខនៅក្នុងបរិយាកាសបទប្បញ្ញត្តិ និងនិន្នាការនៅក្នុងឧស្សាហកម្មគ្រឹះស្ថានហិរញ្ញវត្ថុ។

**ការប្រជុំ ៖** នៅក្នុងឆ្នាំ២០២៣ គណៈកម្មាធិការប្រតិបត្តិបានរៀបចំការប្រជុំប្រចាំសប្តាហ៍ចំនួន ៤៨លើក ដោយបានពិនិត្យលើលទ្ធផលការងារ ពិនិត្យលើផែនការសកម្មភាពការងារ ពិនិត្យដោះស្រាយបញ្ហាដែលបានជួបប្រទះ និងពិភាក្សា ដើម្បីដាក់ចេញនូវផែនការយុទ្ធសាស្រ្តថ្មីៗសម្រាប់អនុវត្ត។

## ២. គណៈកម្មាធិការធនធានមនុស្ស

**សមាសភាព ៖**

| | |
|---|---|
| ❖ អគ្គនាយករង | ប្រធាន |
| ❖ ប្រធាននាយកដ្ឋានធនធានមនុស្ស | អនុប្រធាន |
| ❖ ប្រធាននាយដ្ឋានឥណទាន | សមាជិក |
| ❖ ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងរដ្ឋបាល | សមាជិក |
| ❖ ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង | អ្នកអង្កេតការណ៍ |

**តួនាទី ៖**

- កំណត់លក្ខណៈសម្បត្តិរបស់បេក្ខជនដែលអាចមានគុណវុឌ្ឍិគ្រប់គ្រាន់ ក្នុងការដែលអាចធ្វើជាបុគ្គលិកថ្នាក់ដឹកនាំ ឬអាចត្រូវបានតែងតាំងជាថ្នាក់ដឹកនាំជាន់ខ្ពស់ដោយអនុលោមទៅតាមលក្ខណៈវិនិច្ឆ័យដែលមាន នៅក្នុងគោលការណ៍ និងផ្តល់ជាអនុសាសន៍ជូនដល់ក្រុមប្រឹក្សាភិបាលស្តីពីការតែងតាំង ឬដកចេញពីតំណែង។
- អនុវត្តនូវការវាយតម្លៃការងាររបស់បុគ្គលិក ថ្នាក់ដឹកនាំរបស់អង្គភាព នាយកដ្ឋាន និងសាខា។
- បង្កើតជាទម្រង់ស្តង់ដាររួម សម្រាប់កំណត់គុណវុឌ្ឍិ លក្ខណៈសម្បត្តិវិជ្ជមាន របស់ថ្នាក់ដឹកនាំដែលអាចដឹកនាំប្រកបដោយប្រសិទ្ធភាព។
- សិក្សា និងពិនិត្យឡើងវិញនូវគោលការណ៍ នៃការគណនា និងការរៀបចំកម្រិតប្រាក់បៀវត្សរបស់បុគ្គលិកថ្នាក់ដឹកនាំជាន់ខ្ពស់ ថ្នាក់ដឹកនាំប្រតិបត្តិ និងថ្នាក់គ្រប់គ្រងផ្សេងៗទៀត ដែលជាកម្មវត្ថុសំខាន់ត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាល។

**ការប្រជុំ ៖** គណៈកម្មាធិការធនធានមនុស្សបានរៀបចំការប្រជុំចំនួន ៤លើក ក្នុងឆ្នាំ២០២៣ ដើម្បីពិនិត្យ និងសម្រេចលើការងារមួយចំនួនដូចជា៖ ការជ្រើសរើសនិងតែងតាំងបុគ្គលិក ការវាយតម្លៃបុគ្គលិក ការ

តម្លើង និងការបញ្ចុះឋានៈបុគ្គលិក ការលើកទឹកចិត្ត និងការដាក់ទោសពិន័យបុគ្គលិក។ លើសពីនេះ គណកម្មាធិការក៏បានប្រជុំពិនិត្យ និងអនុម័តលើគោលការណ៍ និងនីតិវិធីធនធានមនុស្សមួយចំនួនផងដែរដូចជាៈ គោលការណ៍ប្រតិបត្តិគ្រប់គ្រងធនធានមនុស្ស គោលការណ៍ហ្វឹកហ្វឺនក្រមសីលធម៌ (Code of Conduct) របាយកំហុសធ្ងន់របស់បុគ្គលិក តួនាទី ការទទួលខុសត្រូវរបស់បុគ្គលិក (JD) និងនីតិវិធីវាយតម្លៃបុគ្គលិកជាដើម។

## ៣. គណៈកម្មាធិការឥណទាន

**សមាសភាព ៖**

| | |
|---|---|
| ❖ អគ្គនាយករង | ប្រធាន |
| ❖ ប្រធាននាយកដ្ឋានឥណទាន | អនុប្រធាន |
| ❖ ប្រធាននាយកដ្ឋានហានិភ័យ និងប្រតិបត្តិតាម | សមាជិក |
| ❖ ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងរដ្ឋបាល | សមាជិក |
| ❖ ប្រធានផ្នែកវិភាគ និងវាយតម្លៃឥណទាន | សមាជិក និងជាលេខាកត់ត្រា |
| ❖ ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង | អ្នកអង្កេតការណ៍ |

**តួនាទី ៖**

- ពិនិត្យ និងអនុម័តឥណទានដែលស្ថិតនៅក្នុងទំហំនៃសិទ្ធិអនុម័តរបស់ខ្លួន។
- ពិនិត្យ និងអនុម័តលើគោលការណ៍ឥណទាន គោលការណ៍ប្រតិបត្តិ និងទម្រង់គម្រូឥណទាន និងនីតិវិធីឥណទាន។
- ពិនិត្យ និងវាយតម្លៃអំពីស្ថានភាពទីផ្សារឥណទាន និងហានិភ័យឥណទាន។
- ពិនិត្យ និងតាមដានលើគុណភាពឥណទាន។
- ពិនិត្យ និងសម្រេចលើផលិតផលថ្មីដែលស្នើដោយនាយកដ្ឋានឥណទាន។
- វិភាគកម្រិតហានិភ័យ និងភាពស្របច្បាប់នៃការផ្តល់ឥណទាន។

**ការប្រជុំ ៖** នៅក្នុងឆ្នាំ២០២៣ គណៈកម្មាធិការឥណទានបានរៀបចំការប្រជុំចំនួន ៧៩លើក ដើម្បីពិនិត្យ និងសម្រេចលើការងារមួយចំនួនដូចជាៈ ប្រជុំពិនិត្យ និងអនុម័តលើគោលការណ៍ និងនីតិវិធីឥណទាន គោលការណ៍ប្រតិបត្តិឥណទាន នីតិវិធីវាយតម្លៃឥណទាន និងការប្រជុំសម្រេចអនុម័តឥណទាន។

## ៤. គណៈកម្មាធិការគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យា

**សមាសភាព ៖**

| | |
|---|---|
| ❖ ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងរដ្ឋបាល | ប្រធាន |
| ❖ ប្រធាននាយកដ្ឋានព័ត៌មានវិទ្យា | អនុប្រធាន |
| ❖ ប្រធាននាយដ្ឋានឥណទាន | សមាជិក |
| ❖ ប្រធាននាយកដ្ឋានធនធានមនុស្ស | សមាជិក |
| ❖ ប្រធាននាយកដ្ឋានគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម | សមាជិក |
| ❖ ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង | អ្នកអង្កេតការណ៍ |

**តួនាទី ៖**

- ពិនិត្យឡើងវិញលើការវាស់វែងការអនុវត្តព័ត៌មានវិទ្យា និងការរួមចំណែករបស់ព័ត៌មានវិទ្យាដល់អាជីវកម្ម។
- ផ្តល់អនុសាសន៍អំពីផលិតផលហេដ្ឋារចនាសម្ព័ន្ធ និងផ្តល់នូវការណែនាំទាក់ទងនឹងស្តង់ដារបច្ចេកវិទ្យា និងការអនុវត្តហើយថែមទាំងធានាថាការវាយតម្លៃភាពងាយរងគ្រោះនៃបច្ចេកវិទ្យាថ្មីត្រូវបានអនុវត្ត។
- ធានាការអនុលោមតាមតម្រូវការ បទប្បញ្ញត្តិ និងច្បាប់ដោយផ្ទៀងផ្ទាត់ការអនុលោមតាមបទដ្ឋានបច្ចេកវិទ្យា និងគោលការណ៍ណែនាំ។
- គណៈកម្មាធិការត្រូវពិនិត្យ ឬពិភាក្សាតាមគោលការណ៍របស់គ្រឹះស្ថាន ឱ្យសមស្របនឹងឯកសារអភិបាលកិច្ចផ្សេងទៀតទាក់ទងនឹងបច្ចេកវិទ្យា រួមទាំងគុណភាព និងប្រសិទ្ធភាពនៃសុវត្ថិភាពបច្ចេកវិជ្ជាព័ត៌មាន ព្រមទាំងភាពធន់នៃអាជីវម្មកម្មតាមយុទ្ធសាស្ត្រដែលបានគ្រោងទុក។
- ពិនិត្យមើលវឌ្ឍនភាពនៃគម្រោងព័ត៌មានវិទ្យា ដោយប្រៀបធៀបរបាយការណ៍ស្ថានភាពគម្រោងជាមួយផែនការ វាយតម្លៃសំណើគម្រោងព័ត៌មានវិទ្យា និងការអនុវត្ត ឬបញ្ចប់វា ការវិភាគដោយផ្អែកលើភាពជោគជ័យ ភាពបរាជ័យរបស់គម្រោង និងវាយតម្លៃផលប៉ះពាល់នៃការកែប្រែ ឬការផ្លាស់ប្តូរនៅក្នុងផែនការ។
- ដំណើរការដើម្បីកំណត់អត្តសញ្ញាណ និងវាយតម្លៃតម្រូវការប្រព័ន្ធព័ត៌មានវិទ្យានាពេលអនាគត។ ត្រូវប្រាកដថាគោលនយោបាយ និងផែនការរបស់ព័ត៌មានវិទ្យាស្របតាមអាណត្តិ និងផែនការអាជីវកម្មរបស់គ្រឹះស្ថាន ដោយអនុលោមតាមស្តង់ដារសវនកម្មខាងក្នុង និងខាងក្រៅអនុលោមតាមគោលនយោបាយ និងផែនការរបស់រដ្ឋាភិបាលដែលមានស្រាប់ និងស្តង់ដារគ្រប់គ្រងហានិភ័យដែលប្រសើរឡើង។

**ការប្រជុំ ៖** នៅក្នុងឆ្នាំ២០២៣ គណៈកម្មាធិការបានរៀបចំប្រជុំចំនួន ៤ដង ដើម្បីពិនិត្យ និងអនុម័តកិច្ចការមួយចំនួនដូចជា៖ ពិនិត្យ និងអនុម័តលើការជ្រើសរើសទិញប្រព័ន្ធធនាគារស្នូល ត្រួតពិនិត្យ និងអនុម័តលើគោលការណ៍ព័ត៌មានវិទ្យា ពិនិត្យលើហានិភ័យទាក់ទងនឹងបច្ចេកវិទ្យាព័ត៌មាន និងកំណត់ស្តង់ដារនៃការប្រើប្រាស់ឧបករណ៍-គ្រឿងអេឡិចត្រូនិកជាដើម។

## ៥. គណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម

**សមាសភាព ៖**

| | |
|---|---|
| ❖ ប្រធាននាយកដ្ឋានគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម | ប្រធាន |
| ❖ ប្រធាននាយកដ្ឋានឥណទាន | អនុប្រធាន |
| ❖ ប្រធាននាយកដ្ឋានព័ត៌មានវិទ្យា | សមាជិក |
| ❖ ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងរដ្ឋបាល | សមាជិក |
| ❖ ប្រធាននាយកដ្ឋានធនធានមនុស្ស | សមាជិក |
| ❖ ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង | អ្នកអង្កេតការណ៍ |

**តួនាទី ៖**

- បង្កើតយុទ្ធសាស្ត្រ និងកំណត់គោលការណ៍សម្រាប់ការការពារ ការគ្រប់គ្រងហានិភ័យ តាមប្រភេទនៃហានិភ័យនីមួយៗរបស់គ្រឹះស្ថាន ដោយផ្អែកលើការកំណត់អត្តសញ្ញាណហានិភ័យ ការវិភាគ ការវាយតម្លៃហានិភ័យ ការធ្វើចំណាត់ថ្នាក់អាទិភាពហានិភ័យ ដំណើរការកាត់បន្ថយហានិភ័យ ការត្រួតពិនិត្យ និងការរាយការណ៍ហានិភ័យ។
- ធ្វើការពិនិត្យឡើងវិញនូវបញ្ហាដែលបានលើកឡើងដោយសវនកម្មផ្ទៃក្នុង ដែលប៉ះពាល់ដល់ក្របខ័ណ្ឌគ្រប់គ្រងហានិភ័យ។
- តាមដានបញ្ហាដែលកំពុងកើតមាន និងនិន្នាការទាក់ទងនឹងការគ្រប់គ្រងហានិភ័យ។
- ធ្វើការពិនិត្យមើលការឆ្លើយតបរបស់អ្នកគ្រប់គ្រងចំពោះអនុសាសន៍របស់សវនករនៃគ្រឹះស្ថានថាត្រូវបានទទួលយកដើម្បីកែតម្រូវ។
- ផ្តល់អនុសាសន៍ទៅអគ្គនាយកអំពីហានិភ័យដែលមានសក្តានុពល និងរាយការណ៍ជូនប្រធានក្រុមប្រឹក្សាភិបាល។

**ការប្រជុំ ៖** នៅឆ្នាំ២០២៣ គណៈកម្មាធិការបានធ្វើការប្រជុំចំនួន ៤លើក ដោយប្រជុំ ដើម្បីពិនិត្យ និងវាយតម្លៃលើហានិភ័យរបស់គ្រឹះស្ថានទាំងមូលដូចជា៖ ពិនិត្យ និងវាយតម្លៃហានិភ័យឥណទាន ហានិភ័យប្រតិបត្តិការ ហានិភ័យនៃការអនុវត្តច្បាប់ និងបទប្បញ្ញត្តិរបស់ធនាគារជាតិ។ គណៈកម្មាធិការក៏បានប្រជុំពិនិត្យ វាយតម្លៃ និងកំណត់ការគ្រប់គ្រងលើហានិភ័យនៃបញ្ហាដែលបានរកឃើញដោយសវនកម្មផ្ទៃក្នុង (Audit finding issues)។

## ៦. ការគ្រប់គ្រងហានិភ័យ

### ក. ការកំណត់ការទទួលខុសត្រូវ

រចនាសម្ព័ន្ធគ្រប់គ្រងរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដែលត្រូវបានកំណត់ឡើង និងអនុវត្តស្របទៅតាមខ្សែបន្ទាត់ការពារទាំងពថ្នាក់ ដោយអនុលោមតាមការៀបចំឡើងរបស់គណៈកម្មាធិការបាសែល ដោយចំណាត់ថ្នាក់នៃការការពារនីមួយៗមានតួនាទី និងទំនួលខុសត្រូវទៅតាមជំនាញរៀងៗខ្លួន ដូចខាងក្រោម៖

- **បន្ទាត់ការពារទី១:** សំដៅផ្នែកប្រតិបត្តិការអាជីវកម្មដែលជាម្ចាស់ហានិភ័យផ្ទាល់។ ពួកគេទទួលយក និងគ្រប់គ្រងរាល់ប្រភេទហានិភ័យទាំងអស់ដែលអាចកើតមានឡើងក្នុងពេលធ្វើប្រតិបត្តិការអាជីវកម្មរបស់គ្រឹះស្ថាន។
- **បន្ទាត់ការពារទី២:** សំដៅដល់ផ្នែកគ្រប់គ្រងហានិភ័យ និងផ្នែកប្រតិបត្តិតាមដែលទទួលខុសត្រូវក្នុងការគ្រប់គ្រងហានិភ័យក្នុងគ្រឹះស្ថានទាំងមូលព្រមទាំងបញ្ហាប្រតិបត្តិតាមនានាដែលរួមមាន៖ ការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ដែលគាំទ្រដល់កម្មភាពភេរវកម្ម។ ផ្នែកគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម គឺជាផ្នែកឯករាជ្យហើយផ្នែកទាំងពីរនេះត្រូវរាយការណ៍ដោយផ្ទាល់ទៅកាន់គណៈកម្មាធិការគ្រប់គ្រងហានិភ័យ។
- **បន្ទាត់ការពារទី៣:** សំដៅដល់ផ្នែកសវនកម្មផ្ទៃក្នុងដែលមានតួនាទី និងទំនួលខុសត្រូវចម្បងៗ រួមមាន៖ ការចុះធ្វើសវនកម្មទូទៅ និងសវនកម្មដែលផ្អែកលើកត្តាហានិភ័យ ដើម្បីពិនិត្យមើលឡើងវិញ និងផ្តល់ការធានាជូនចំពោះក្រុមប្រឹក្សាភិបាល ដោយធ្វើឱ្យប្រាកដថាក្របខ័ណ្ឌអភិបាលកិច្ចទាំងមូលរួមមាន៖ ក្របខ័ណ្ឌនៃការគ្រប់គ្រងហានិភ័យ យុទ្ធសាស្ត្រ និងគោលដៅ

របស់គ្រឹះស្ថាន គឺត្រូវបានអនុវត្តយ៉ាងមានប្រសិទ្ធភាព និងសមស្របតាមការយល់ព្រមរបស់ក្រុមប្រឹក្សាភិបាល។ ផ្នែកសវនកម្មផ្ទៃក្នុងក៏ត្រូវធានាផងដែរថារាល់គោលការណ៍នីតិវិធី ដែលមានស្រាប់ត្រូវបានអនុវត្តហើយគោរពតាមបន្ទាត់ការពារថ្នាក់ទី១ និងថ្នាក់ទី២។

**ការការពារថ្នាក់ទី១**

**ផ្នែកអាជីវកម្ម**

- កំណត់អត្តសញ្ញាណ និងគ្រប់គ្រងហានិភ័យក្នុងប្រតិបត្តិការប្រចាំថ្ងៃ
- ប្រតិបត្តិការអាជីវកម្មក្នុងកម្រិតហានិភ័យដែលអាចអនុគ្រោះបាន
- អនុវត្តប្រតិបត្តិការអាជីវកម្មតាមគោលការណ៍ណែនាំ និងគោលនយោបាយ។

**ការការពារថ្នាក់ទី២**

**ការគ្រប់គ្រងហានិភ័យ**

- ផ្សព្វផ្សាយវប្បធម៌ និងការយល់ដឹងអំពីការគ្រប់ គ្រងហានិភ័យ
- ត្រួតពិនិត្យ និងរាយការ-ណ៍អំពីការអនុវត្តហានិភ័យរួមទាំងការប្រតិបត្តិតាមបទប្បញ្ញត្តិ។

**ការការពារថ្នាក់ទី៣**

**សវនកម្មផ្ទៃក្នុង**

- ផ្តល់ការធានាឯករាជ្យភាពអំពីប្រសិទ្ធភាពនសការគ្រប់គ្រងហានិភ័យដំណើរការការគ្រប់គ្រងផ្ទៃក្នុង និងប្រពន្ធ័ដេលអនុវត្តដោយការពារថ្នាក់ទីមួយ និងទីពីរ
- ពិនិត្យមើលប្រសិទ្ធភាពនៃការគ្រប់គ្រង និងផ្តល់យោបល់ដល់ថ្នាក់ទីមួយ និងទីពីរ។

## ខ. ប្រភេទហានិភ័យ

គ្រឹះស្ថាន វ៉ាយ.អិល.ភី មីក្រូហិញ្ញវត្ថុ ម.ក បានយកចិត្តទុកដាក់បំផុតទៅលើហានិភ័យផ្សេងៗ ដែលអាចកើតឡើងនាំឱ្យប៉ះពាល់ដល់ប្រតិបត្តិការនៅពេលកំពុងដំណើរការ និងអាចធ្វើឱ្យមានការខាតបង់ផ្សេងៗជាដើម។

ហានិភ័យសំខាន់ៗដែលគ្រឹះស្ថានត្រូវយកចិត្តទុកដាក់ខ្ពស់ក្នុងការគ្រប់គ្រងមានដូចខាងក្រោម៖

### ☞ ហានិភ័យវិស័យសេដ្ឋកិច្ច




ប្រទេសកម្ពុជាពឹងផ្អែកលើវិស័យសេដ្ឋកិច្ចសំខាន់ៗចំនួនបីដែលវិស័យនីមួយៗមានភាពផុយស្រួយ ទៅតាមស្ថានភាពរៀងៗខ្លួន ដូចជា៖ ទេសចរណ៍ ដែលបានរងផលប៉ះពាល់ដោយបញ្ហាជម្ងឺកូវីដ-១៩ កន្លងមក ដែលមានផលប៉ះពាល់យ៉ាងខ្លាំង។ បញ្ហាចលនានយោបាយនៅក្នុងតំបន់ និងអំពើភេរវកម្ម ដែលភាគច្រើនស្ថិតនៅក្រៅការគ្រប់គ្រងរបស់ប្រទេស។ ទោះជាយ៉ាងណាក៏ដោយ គ្រឹះស្ថានត្រូវតែបន្តដំណើរទៅមុខ ដើម្បីត្រៀមខ្លួនចូលរួមស្តារវាឡើងវិញឱ្យមានភាពប្រសើរឡើងជាបន្តបន្ទាប់។ វិស័យដែលនាំមុខមួយទៀតគឺ ឧស្សាហកម្មកាត់ដេរ ដែលបច្ចុប្បន្នកំពុងមានដំណើរការឡើងវិញជាបន្តបន្ទាប់ក្រោយពីរងផលប៉ះពាល់ពីជម្ងឺកូវីដ-១៩ ទោះបីនៅមានបញ្ហាទីផ្សារ ការនាំចេញ និងខ្វះខាតវត្ថុធាតុដើមក្នុងការផលិតជាដើម។ គ្រឹះស្ថាននឹងធ្វើការផ្តល់ឥណទាននៅក្នុងវិស័យនេះ ដោយមានការសម្រិតសម្រាំងយ៉ាងយកចិត្តទុកដាក់បំផុត។ ជាចុងក្រោយវិស័យកសិកម្ម គឺជាកត្តាជំរុញដ៏

សំខាន់នៃសេដ្ឋកិច្ចជនបទ ទោះជាវិស័យនេះមានបញ្ហាខ្លះៗទាក់ទងនឹងទីផ្សារ កត្តាធម្មជាតិ និងកត្តាផលិតផលក៏ដោយ ក៏គ្រឹះស្ថាននឹងយកចិត្តទុកដាក់បន្ថែមទៀត ដើម្បីជួយជម្រុញឱ្យវិស័យនេះបន្តរីកចម្រើនជាបន្តបន្ទាប់។

## ហានិភ័យប្រតិបត្តិការ



វាគឺជាហានិភ័យនៃការបាត់បង់ដោយផ្ទាល់ ឬដោយប្រយោល ដោយសារព្រឹត្តិការណ៍ ឬសកម្មភាពដែលបណ្តាលឱ្យបរាជ័យនៃដំណើរការបច្ចេកវិទ្យា ហេដ្ឋារចនាសម្ព័ន្ធបុគ្គលិក និងហានិភ័យផ្សេងទៀតដែលមានផលប៉ះពាល់ហានិភ័យប្រតិបត្តិការ។ ខណៈពេលដែលហានិភ័យប្រតិបត្តិការវាគឺជាទំនួលខុសត្រូវរបស់អ្នកគ្រប់គ្រងទាំងអស់ក្នុងការធានានូវក្របខណ្ឌការគ្រប់គ្រង ហានិភ័យសមស្រប និងដើម្បីត្រួតពិនិត្យ ព្រមទាំងគ្រប់គ្រងហានិភ័យប្រតិបត្តិការ។ អគ្គនាយក និងអ្នកគ្រប់គ្រងមានទំនួលខុសត្រូវក្នុងការបង្កើត ធ្វើបច្ចុប្បន្នភាព និងសាកល្បងជាប្រចាំនូវផែនការបន្តអាជីវកម្ម។

## ហានិភ័យឥណទាន




ជាហានិភ័យមួយសំដៅដល់ ហានិភ័យដែលសមភាគីមិនអាចអនុវត្តបានតាមកាតព្វកិច្ចដែលមានចែងក្នុងកិច្ចសន្យា ឬអាចនិយាយបានថាគឺជាឱកាសដែលកូនបំណុល ឬអ្នកប្រើប្រាស់ហិរញ្ញវត្ថុ (ប្រាក់កម្ចី) មិនអាចសងការប្រាក់ ឬសងប្រាក់ដើមតាមពេលវេលា ដែលបានកំណត់ជាក់លាក់នៅក្នុងកិច្ចសន្យាផ្តល់ឥណទាន។ ដូចនេះគ្រឹះស្ថាន វ៉ាយ.អិល.ភី មីក្រូហិរញ្ញវត្ថុ ម.ក បានប្រើប្រាស់ការវាស់វែងហានិភ័យឥណទាន និងហានិភ័យដាច់ដោយឡែកតាមកម្រិតនៃអតិថិជននីមួយៗ នឹងធ្វើការចុះដល់កន្លែងអាជីវកម្មជាដើម។ ដើម្បីសម្រេចបាននូវ កំណើនឥណទានប្រកបដោយគុណភាព និងដើម្បីពង្រឹងលើយន្តការគ្រប់គ្រងហានិភ័យឥណទានដ៏រឹងមាំ យន្តការទាំងនោះត្រូវបានកំណត់ដោយជាក់លាក់ និងអនុម័តដោយក្រុមប្រឹក្សាភិបាល ដែលមាននៅក្នុងគោលការណ៍ឥណទាន។

## ហានិភ័យប្រតិបត្តិតាម និងបទប្បញ្ញត្តិ




ហានិភ័យនេះសំដៅទៅលើការមិនអនុលោមតាមតម្រូវការ និងបទប្បញ្ញត្តិដែលមាននៅក្នុងប្រទេសកម្ពុជាយើង។ មុខងារគ្រប់គ្រងហានិភ័យនៃការអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិគឺទទួលខុសត្រូវក្នុងការបង្កើត និងរក្សាក្របខណ្ឌសមស្របនៃគោលនយោបាយ និងនីតិវិធីនៃការប្រតិបត្តិតាម។ ការអនុលោមតាមគោលការណ៍ និងនីតិវិធីទាំងនេះគឺជាការទទួលខុសត្រូវរបស់អ្នកគ្រប់គ្រងទាំងអស់។ គ្រឹះស្ថាននឹងធ្វើការតាមដានរាល់កិច្ចការទាំងអស់ ដើម្បីធានាបាននូវការ

អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធទាំងអស់ ហើយគោលនយោបាយ និងការត្រួតពិនិត្យសមស្របគឺធ្វើឡើងដើម្បីផ្តល់នូវស្តង់ដារខ្ពស់បំផុតនៃអភិបាលកិច្ច អាជីវកម្ម និងមានអាកប្បកិរិយាប្រកបដោយសីលធម៌។

### ☞ ហានិភ័យសាច់ប្រាក់ងាយស្រួល




គ្រឹះស្ថាន វ៉ាយ.អិល.ភី មីក្រូហិរញ្ញវត្ថុ ម.ក ផ្តល់ជូនសេវាកម្មឥណទានតែប៉ុណ្ណោះ ដូចនេះចំពោះហានិភ័យសាច់ប្រាក់ងាយស្រួល គឺមិនមានអ្វីដែលធ្វើអោយប៉ះពាល់ដល់គ្រឹះស្ថានឡើយ។

## ៧. ការប្រឆាំងការខារសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម




ក្នុងដំណើរការប្រតិបត្តិតាមច្បាប់/ប្រកាស ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញញប្បទានភេរវកម្ម និងសេចក្តីណែនាំថ្មី របស់ធនាគារជាតិនៃកម្ពុជា ក៏ដូចជាអង្គភាពស៊ើបការហិរញ្ញវត្ថុនៃកម្ពុជា គ្រឹះស្ថាន វ៉ាយ.អិល.ភី មីក្រូហិរញ្ញវត្ថុ ម.ក បានយកចិត្តទុកដាក់យ៉ាងខ្លាំងលើការត្រួតពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពលើគោលការណ៍នីតិវិធីរបស់ខ្លួន។ ក្នុងគោលបំណងដើម្បីធ្វើការតាមដានលើប្រតិបត្តិការរបស់អតិថិជន ក៏ដូចជាការចាត់វិធានការយកចិត្តទុកដាក់ស្គាល់អតិថិជនជាដើម។ លើសពីនេះគ្រឹះស្ថានបានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការអនុវត្តនូវស្តង់ដារអន្តរជាតិក្នុងការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវបទប្បញ្ញត្តិទាំងឡាយរបស់អាជ្ញាធរមានសមត្ថកិច្ច។

ក្នុងយន្តការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ផ្នែកប្រតិបត្តិតាមបានធ្វើបច្ចុប្បន្នភាពអំពីបញ្ជីខ្មៅរបស់ឯកត្តបុគ្គល នីតិបុគ្គលដែលពាក់ព័ន្ធ ដែលបានចេញដោយធនាគារជាតិនៃកម្ពុជា ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ និងភាគីពាក់ព័ន្ធដ៏ទៃទៀតទៅតាមសាខា ដើម្បីធ្វើការផ្ទៀងផ្ទាត់ឈ្មោះ និងធានាថារាល់ពេលទំនាក់ទំនងអាជីវកម្មជាមួយអតិថិជនត្រូវបានត្រួតពិនិត្យយ៉ាងត្រឹមត្រូវ។ ចំពោះការអនុវត្ត“ការស្គាល់អតិថិជន” ឬ “ការយកចិត្តទុកដាក់ស្គាល់អតិថិជន” វាជាចំណុចសំខាន់ ដែលគ្រឹះស្ថាន វ៉ាយ.អិល.ភី មីក្រូហិរញ្ញវត្ថុ ម.ក បានដាក់ក្នុងវគ្គបណ្តុះបណ្តាលទៅលើការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មដល់បុគ្គលិកថ្មី ក៏ដូចជាការបណ្តុះណ្តាលរំលឹកឡើងវិញទៅកាន់បុគ្គលិកដែលពាក់ព័ន្ធទាំងអស់។

ចំពោះការរាយការណ៍របាយការណ៍ប្រតិបត្តិការសង្ស័យ និងរបាយការណ៍ប្រតិបត្តិការសាច់ប្រាក់ ឬរបាយការណ៍ផ្សេងៗដែលតម្រូវដោយអង្គភាពស៊ើបការហិរញ្ញវត្ថុកម្ពុជា គ្រឹះស្ថាន វ៉ាយ.អិល.ភី មីក្រូហិរញ្ញវត្ថុ ម.ក បានធ្វើជូនទៅអង្គភាពស៊ើបការហិរញ្ញវត្ថុកម្ពុជាបានយ៉ាងទៀងទាត់ និងទាន់ពេលវេលា។

### ៨. ការត្រួតពិនិត្យផ្ទៃក្នុង

ដើម្បីធានាថាប្រតិបត្តិការរបស់គ្រឹះស្ថានអនុលោមទៅតាមបទប្បញ្ញត្តិច្បាប់ គោលការណ៍នីតិវិធី និងជួយឱ្យគ្រឹះស្ថានសម្រេចបានគោលដៅអាជីវកម្មរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព គ្រឹះស្ថានបានរៀបចំឱ្យមានប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដោយបង្កើតឱ្យមាននាយកដ្ឋានគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម និងនាយកដ្ឋានសវនកម្មផ្ទៃក្នុងដោយបានកំណត់តួនាទី និងការទទួលខុសត្រូវដូចខាងក្រោម៖

❖ **នាយកដ្ឋានគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម**

- ទទួលខុសត្រូវក្នុងការផ្ដើមគំនិត និងធ្វើបច្ចុប្បន្នភាពគោលការណ៍ និងនីតិវិធី ដើម្បីធានាថាការអនុវត្តគឺស្របតាមច្បាប់ បទប្បញ្ញត្តិ បទដ្ឋានគតិយុទ្ធនានា និងមានលក្ខណៈស្តង់ដារការងារ។
- ធ្វើការផ្សព្វផ្សាយនូវច្បាប់ បទប្បញ្ញត្តិ និងលិខិតបទដ្ឋានគតិយុត្ត ដល់គណៈគ្រប់គ្រង និងការិយាល័យ។
- មុខងារគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម គឺឯករាជ្យដើម្បីរាយការណ៍ទៅអ្នកគ្រប់គ្រងជាន់ខ្ពស់អំពីការបំពានណាមួយ ការមិនអនុលោមតាមគោលការណ៍ ឬគោលនយោបាយ ច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។ នេះមានន័យថានាយកដ្ឋានគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាមអាចអនុវត្តមុខងាររបស់ខ្លួនតាមគំនិតផ្តួចផ្តើមរបស់ខ្លួនដោយគ្មានការរារាំង និងការភ័យខ្លាចចំពោះការសងសឹកពីថ្នាក់ដឹកនាំ និងបុគ្គលិកដទៃទៀត។

❖ **នាយកដ្ឋានសវនកម្មផ្ទៃក្នុង**

- ចាត់ចែង និងដឹកនាំក្នុងការរៀបចំផែនការសវនកម្មប្រចាំឆ្នាំ។
- ទទួលខុសត្រូវក្នុងការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលការណ៍នីតិវិធី ឱ្យមានប្រសិទ្ធិភាពខ្ពស់។
- សម្របសម្រួល និងបង្កើតដំណើរការសវនកម្មផ្ទៃក្នុង។
- ត្រួតពិនិត្យ និងធ្វើសវនកម្មផ្ទៃក្នុងនៅក្នុងគ្រឹះស្ថាន។
- ធ្វើការស៊ើបអង្កេតលើភាពមិនប្រក្រតី និងការក្លែងបន្លំ។
- រៀបចំរបាយការណ៍ពីភាពមិនប្រក្រតីដែលបានរកឃើញ និងផ្តល់អនុសាន៍ជូនក្រុមប្រឹក្សាភិបាល។
- ផ្តល់ជាអនុសាសន៍ដល់អគ្គនាយក។
- ធ្វើការវាយតម្លៃដោយឯករាជ្យ គ្រប់ជ្រុងជ្រោយ និងមានប្រសិទ្ធភាពខ្ពស់ក្នុងប្រតិបត្តិការរបស់គ្រឹះស្ថាន និងធ្វើរបាយការណ៍ដោយផ្ទាល់ជូនទៅក្រុមប្រឹក្សាភិបាល។

# VI. ការគ្រប់គ្រងធនធានមនុស្ស

គ្រឹះស្ថាន វ៉ាយ.អិល.ភី មីក្រូហិរញ្ញវត្ថុ ម.ក បានយកចិត្តទុកដាក់ខ្ពស់បំផុតទៅលើកិច្ចប្រតិបត្តិការ ការងាររៀបចំធនធានមនុស្ស ដោយអនុវត្តទៅតាមគោលការណ៍គ្រប់គ្រងធនធានមនុស្ស បទបញ្ជាផ្ទៃក្នុង គោលការណ៍ប្រតិបត្តិ និងបទប្បញ្ញត្តិ ក៏ដូចជានីតិវិធីនានាដែលត្រូវបានបង្កើតឡើងដោយគ្រឹះស្ថាន និងអនុឡោមទៅតាមច្បាប់ស្តីពីការងារនៃព្រះរាជាណាចក្រកម្ពុជា។

## ១. ការជ្រើសរើសបុគ្គលិក




ការជ្រើសរើសបុគ្គលិក គឺត្រូវបានធ្វើឡើងស្របតាមគោលការណ៍គ្រប់គ្រងធនធានមនុស្សរបស់គ្រឹះស្ថាន ដោយបានប្រកាសជ្រើសរើសបេក្ខជន-បេក្ខនារីពីខាងក្នុង-ខាងក្រៅ និងបានធ្វើការផ្សព្វផ្សាយតាមបណ្ដាញសង្គម (Facebook page, Facebook account, Telegram group and Channels) និងតាមរយៈមជ្ឈមណ្ឌលស្វែងរកការងារខេត្ត តាមបណ្ដាសាលារៀន សាកលវិទ្យាល័យ បណ្ដាញបុគ្គលិក និងដៃគូរផ្សេងៗ ដោយមានគណៈកម្មាធិការជ្រើសរើសបុគ្គលិក ដើម្បីសម្រិតសម្រាំង សម្ភាស និងជ្រើសរើសបេក្ខជន-បេក្ខនារីដែលមាន ចំណេះដឹង ជំនាញ អាកប្បកិរិយា និងគុណវុឌ្ឍិត្រឹមត្រូវតាមតួនាទីការងារនីមួយៗ។ គ្រឹះស្ថាន វ៉ាយ.អិល.ភី មីក្រូហិរញ្ញវត្ថុ ម.ក ផ្ដល់ឱកាសការងារដល់បេក្ខជនស្មើភាពគ្នាដោយមិនប្រកាន់នូវពូជសាសន៍ ពណ៌សម្បុរ ភេទ ជំនឿ សាសនា និងដើមកំណើតក្នុងសង្គមឡើយ។ ដើម្បីជាការឆ្លើយតបទៅនឹងតម្រូវការចាំបាច់ជាក់ស្ដែង គ្រឹះស្ថានបានបន្តធ្វើការជ្រើសរើសបុគ្គលិកជាបន្តបន្ទាប់ ក្នុងកំឡុងឆ្នាំ២០២៣នេះ ដោយបានធ្វើការជ្រើសរើសបុគ្គលិកបន្ថែមថ្មីសរុបចំនួន១៦នាក់ (ស្រី០៣នាក់)។

## ២. ការអភិវឌ្ឍសមត្ថភាពបុគ្គលិក




គ្រប់បុគ្គលិកថ្មីទាំងអស់របស់គ្រឹះស្ថាន វ៉ាយ.អិល.ភី មីក្រូហិរញ្ញវត្ថុ ម.ក មុននឹងប្រគល់ការងារឱ្យបំពេញ នឹងត្រូវបានទទួលការហ្វឹកហ្វឺនដោយក្រុមគ្រូហ្វឹកហ្វឺនទៅតាមតួនាទី និងជំនាញរបស់ខ្លួនចំនួន ១៩មុខវិជ្ជាដើម្បីឱ្យប្រាកដថា បុគ្គលិកទាំងនោះមានចំណេះ ជំនាញ និងវិជ្ជាជីវៈគ្រប់គ្រាន់ក្នុងការបំពេញការងារ។ ទន្ទឹមនឹងនេះ ចំពោះបុគ្គលិកចាស់ដែលបាន នឹងកំពុងបំពេញការងារស្រាប់ គ្រឹះស្ថានតម្រូវឱ្យអ្នកគ្រប់គ្រងផ្ទាល់របស់ខ្លួន ត្រូវផ្ដល់ការហ្វឹកហ្វឺនប្រចាំខែដល់បុគ្គលិករបស់ខ្លួន យ៉ាងតិច ២ដង ក្នុង១ខែ ដើម្បីឱ្យបុគ្គលិកមានចំណេះជំនាញទាន់សម័យស្របតាមការវិវឌ្ឍន៍របស់ស្ថាប័ន និងច្បាប់បញ្ញត្តិ។

នៅក្នុងឆ្នាំ២០២៣ គ្រឹះស្ថានបានផ្ដល់ការបណ្ដុះបណ្ដាលដល់បុគ្គលិកទាំងអស់សរុបចំនួន ៨៣នាក់ (ស្រី ១៧នាក់) ក្នុងនោះបុគ្គលិកថ្មីចំនួន ១៦នាក់ និងបុគ្គលិកចាស់ចំនួន ៦៧នាក់។ ក្រៅពីនេះ គ្រឹះស្ថានបានបញ្ជូនបុគ្គលិកទៅបណ្ដុះបណ្ដាលនៅខាងក្រៅស្ថាប័នចំនួន ០២នាក់។ លើសពីនេះទៅទៀត គ្រឹះស្ថានក៏បានរៀបចំផ្ដល់វគ្គបណ្ដុះបណ្ដាល និងវគ្គសិក្ខាសាលាផ្សេងៗទៀតចំនួន ៣វគ្គ ដល់គ្រូបង្គោល និងបុគ្គលិកពាក់ព័ន្ធ។

### ៣. ការវាយតម្លៃ និងការតែងតាំងបុគ្គលិក

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ វ៉ាយ.អិល.ភី ម.ក បានធ្វើការយកចិត្តទុកដាក់ខ្ពស់លើការវាយតម្លៃស្នាដៃបុគ្គលិក ដើម្បីជម្រុញលើកទឹកចិត្តឱ្យបុគ្គលិកអនុវត្តការងារកាន់តែល្អប្រសើរ និងទទួលបានលទ្ធផលខ្ពស់។ ការវាយតម្លៃស្នាដៃរបស់បុគ្គលិកត្រូវបានធ្វើឡើងដោយផ្អែកលើនីតិវិធីវាយតម្លៃលទ្ធផលការងារជាក់ស្តែងរបស់បុគ្គលិក ដោយយោងតាមលទ្ធផលវាយតម្លៃនៃស្តង់ដារសូចនាករវាយតម្លៃ (KPIs) ដែលបានកំណត់។ ទន្ទឹមនឹងនេះ ការតម្លើងប្រាក់បៀវត្សរ៍អាចប្រព្រឹត្តទៅបានអាស្រ័យលើការកត្តា ២ សំខាន់ គឺ KPI និងប្រាក់ចំណេញរបស់គ្រឹះស្ថាន។

ជាទូទៅ គ្រឹះស្ថានធ្វើការវាយតម្លៃលទ្ធផលការងារបុគ្គលិក ១ដង ក្នុង១ឆ្នាំ (តាមឆ្នាំប្រតិទិន្ន) ដើម្បីតម្លើងប្រាក់បៀវត្សរ៍ ឬតម្លើងឋានៈជាដើម។ ជាក់ស្តែងនៅក្នុងឆ្នាំ ២០២៣ គ្រឹះស្ថានបានវាយតម្លៃបុគ្គលិកសរុបចំនួន ៦៦ នាក់ ក្នុងនោះ ៥០នាក់ បានតម្លើងប្រាក់បៀវត្សរ៍ និង ១៦ នាក់ រក្សាប្រាក់បៀវត្សរ៍ដដែល (ដោយសារមិនទាន់ផុតរយៈពេលសាកល្បងការងារ)។ ចំពោះបុគ្គលិកដែលបានវាយតម្លៃហើយទទួលបានលទ្ធផលល្អ ត្រូវបានដំឡើងតួនាទី និងតម្លើងប្រាក់បៀវត្សរ៍ទៅតាមលទ្ធផលការងារជាក់ស្តែងរៀងៗខ្លួន។




## VII. ការចូលរួមជាមួយសង្គម និងការការពារបរិស្ថាន

### ១. ការចូលរួមជាមួយសង្គម

គ្រឹះស្ថាន វ៉ាយ.អិល.ភី មីក្រូហិរញ្ញវត្ថុ ម.ក បានបើកដំណើរការប្រតិបត្តិការក្នុងដើមឆ្នាំ២០២២។ គ្រឹះស្ថានបានយកចិត្តទុកដាក់ និងខិតខំប្រឹងប្រែងចូលរួមក្នុងការអភិវឌ្ឍសង្គម សេដ្ឋកិច្ចជាតិ និងសុខមាលភាពរបស់បុគ្គលិកជាខ្លាំង។ គ្រឹះស្ថាន វ៉ាយ.អិល.ភី មីក្រូហិរញ្ញវត្ថុ ម.ក ជាស្ថាប័នហិរញ្ញវត្ថុមួយ មានចក្ខុវិស័យ បេសកកម្ម ជម្រុញប្រតិបត្តិការអាជីវកម្មប្រកបដោយការទទួលខុសត្រូវខ្ពស់ចំពោះ បុគ្គលិក អតិថិជន បរិស្ថាន និងសង្គមជាតិ។

❖ **ការចូលរួមជាមួយសង្គមដោយមិនផ្តល់កម្ចីមិនស្របច្បាប់**

- មិនផ្តល់កម្ចីដល់អ្នកប្រើប្រាស់សារធាតុគ្រឿងញៀន ឬជនមានទោសកំពុងរត់គេចខ្លួន។
- មិនផ្តល់កម្ចីដល់មុខរបរខុសច្បាប់ ឬប្រឆាំងនឹងក្រមសីលធម៌សង្គម ដូចជា នេសាទខុសច្បាប់ អាជីវកម្មគ្រឿងញៀន អាជីវកម្មសត្វព្រៃ អាជីវកម្មប្រើប្រាស់កំលាំងពលកម្មកុមារ ការផលិតគ្រឿងសព្វាវុធ ល្បែងស៊ីសង ឬការភ្នាល់ដាក់សាច់ប្រាក់ ឬរបស់មានតម្លៃផ្សេងៗជាដើម។
- មិនផ្តល់កម្ចីដល់ជនដែលមានជាប់ពាក់ព័ន្ធជាមួយនឹងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មជាដើម។

### ❖ ការចូលរួមកាត់បន្ថយភាពក្រីក្រ និងបង្កើនសេដ្ឋកិច្ចជាតិ



- បង្កើនប្រាក់ចំណូលដល់ពលរដ្ឋ តាមរយៈអតិជនដែលបានប្រើប្រាស់ឥណទាន បង្កើតមុខរបរ និងពង្រីកមុខរបរដែលមានស្រាប់នៅតាមមូលដ្ឋាន ភូមិ ឃុំ របស់ពួកគាត់ ដែលអាចកាត់បន្ថយការចំណាកស្រុកទៅធ្វើការនៅក្រៅប្រទេស។
- ផ្តល់ការងារដល់ប្រជាពលរដ្ឋ ក៏ដូចជាសិស្ស-និស្សិត ដែលកំពុង ឬបញ្ចប់ការសិក្សា ដែលធ្វើឱ្យពួកគាត់មានមុខរបរច្បាស់លាស់ និងប្រាក់ចំណូលគ្រប់គ្រាន់ ដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារ។
- ចូលរួមបង្កើនចំណូលជាតិ តាមរយៈការបង់ពន្ធប្រចាំខែ ប្រចាំឆ្នាំ មានដូចជា ពន្ធលើប្រាក់បៀវត្ស ពន្ធលើផលរបរ ពន្ធកាត់ទុក ពន្ធផ្លាកយីហោ ពន្ធមធ្យោបាយធ្វើដំណើរ ពន្ធលើប្រាក់ចំណេញ ពន្ធប៉ាតង់ និងពន្ធផ្សេងៗ។
- បង្រៀនដោយប្រយោលដល់អតិថិជន អោយចេះវិភាគ ចាត់ចែង និងគ្រប់គ្រងប្រាក់ចំណូលរបស់ខ្លួន តាមរយៈការប្រឹក្សាយោបល់ពីមន្ត្រីឥណទានរបស់គ្រឹះស្ថាន វ៉ាយ.អិល.ភី មីក្រូហិរញ្ញវត្ថុ ម.ក។

### ❖ ការឧបត្ថម្ភផ្សេងៗរបស់គ្រឹះស្ថាន

- គ្រឹះស្ថានបានឧបត្ថមទឹកសុទ្ធចំនួន ១០០ យួរ និងថវិការចំនួន ៧៤០ដុល្លារ ដល់ក្រុមកីឡាករអុំទូក ខេត្តបន្ទាយមានជ័យ ក្នុងការបោះពុម្ពអាវ មួកសម្រាប់កីឡាករ និងសម្រាប់ចំណាយផ្សេងៗ។
- គ្រឹះស្ថានបានចូលរួមបរិច្ចាគថវិកាដល់កាកបាទក្រហមកម្ពុជា ខេត្តបន្ទាយមានជ័យ ក្នុងការជួយសម្រាលទុក្ខលំបាកដល់ជនងាយរងគ្រោះដោយគ្រោះធម្មជាតិ និងគ្រោះមហន្តរាយផ្សេងៗ។





## ២. ការចូលរួមក្នុងការការពារបរិស្ថាន



- មិនផ្តល់កម្ចីដល់អាជីវកម្មដែលពាក់ព័ន្ធលើវិទ្យុសកម្ម/ជាតិគីមី ឬជាតិពុលបំផ្លាញបរិស្ថាន
- មិនផ្តល់កម្ចីដល់អាជីវកម្មពាក់ព័ន្ធនិងការកាប់បំផ្លាញព្រៃឈើ
- មិនផ្តល់ឥណទានដល់អតិថិជនដែលយកលុយទៅប្រើប្រាស់ក្នុងគោលដៅខុសច្បាប់ ឬបំផ្លាញបរិស្ថានផ្សេងៗ
- អប់រំបុគ្គលិក កាត់បន្ថយ សន្សំសំចៃ ក្នុងការប្រើប្រាស់ក្រដាស ថង់ផ្លាស្ទិច និងថាមពលអគ្គិសនី

## ៣. ការចូលរួមថែរក្សាវប្បធម៌ប្រពៃណីខ្មែរ

គ្រឹះស្ថានបានចូលរួម និងយកចិត្តទុកដាក់ជាខ្លាំងចំពោះការថែរក្សាវប្បធម៌ប្រពៃណីជាតិខ្មែរ ដោយបានរៀបចំ និងចូលរួមប្រារព្ធពិធីបុណ្យចូលឆ្នាំខ្មែរ បុណ្យភ្ជុំបិណ្ឌ និងបុណ្យអុំទូក ដែលជាបុណ្យប្រពៃណីជាតិខ្មែរ។ នៅក្នុងពិធីបុណ្យប្រពៃណីទាំងនេះគ្រឹះស្ថានបានរៀបចំកម្មវិធីជាច្រើនដូចជា ពិធីសាសនា កម្មវិធីល្បែងល្បាំប្រជាប្រិយ ការរាំលេងកម្សាន្ត ការពិសារភោជនីយអាហារ និងការផ្តល់រង្វាន់ដល់បុគ្គលិក ជាការបង្កើនភាពស្និតស្នាលក្នុងគ្រឹះស្ថាន។



ពិធីសូត្រមន្ត លើករាសី



ពិធីសូត្រមន្ត លើករាសី

កម្រងរូបភាពគណៈគ្រប់គ្រង និងបុគ្គលិក



លេងល្បែងប្រជាប្រិយខ្មែរ



លេងល្បែងប្រជាប្រិយខ្មែរ



លេងល្បែងប្រជាប្រិយខ្មែរ



# VIII.របាយការណ៍ហិរញ្ញវត្ថុ (សវនកម្ម)

## ១. របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

នាថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២៣

| | ២០២៣ | | ២០២២ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **ទ្រព្យសកម្ម** | | | | |
| សាច់ប្រាក់ក្នុងដៃ | ៤៩.៤២១ | ២០១.៨៨៥ | ១១៨.៨១៧ | ៤៨៩.១៧០ |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារជាតិនៃកម្ពុជា | ៧៦.១៥២ | ៣១១.០៨១ | ៧៥.៧២៨ | ៣១១.៧៧២ |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារផ្សេងៗ | ៤១២.៨៤២ | ១.៦៨៦.៤៦០ | ១១០.៦១៤ | ៤៥៥.៣៩៨ |
| ឥណទានផ្តល់ដល់អតិថិជន | ៦.២៥៥.៥៩៧ | ២៥.៥៥៤.១១៤ | ៦.០០៩.៤៧២ | ២៤.៧៤០.៩៩៦ |
| ទ្រព្យសកម្មផ្សេងៗ | ៤០.៣៦២ | ១៦៤.៨៧៩ | ៤៧.៨៩១ | ១៩៧.១៦៧ |
| ទ្រព្យ និងបរិក្ខារ | ១៩៧.៩៩៧ | ៨០៨.៨១៨ | ២៤១.០៩៨ | ៩៩២.៦០០ |
| ទ្រព្យសកម្មអរូបី | ២៣.៦៣១ | ៩៦.៥៣៣ | ៣១.៤៣៨ | ១២៩.៤៣០ |
| **ទ្រព្យសកម្មសរុប** | **៧.០៥៦.០០២** | **២៨.៨២៣.៧៧០** | **៦.៦៣៥.០៥៨** | **២៧.៣១៦.៥៣៣** |
| **បំណុល និងមូលធន** | | | | |
| **បំណុល** | | | | |
| បំណុលផ្សេងៗ | ១០៩.៦១៣ | ៤៤៧.៧៧២ | ១២២.៧៩៩ | ៥០៥.៥៦៣ |
| បំណុលពន្ធអប្បបរមា | ៨៧៦ | ៣.៥៧៨ | ៨២៣ | ៣.៣៨៨ |
| ប្រាក់កម្ចីពីភាគទុនិក | ៩៩១.៨២៥ | ៤.០៥១.៦០៥ | ៥.៤៩៣.៤៧៩ | ២២.៦១៦.៦៥៣ |
| អនុបំណុល | ៥.០១០.៨៦១ | ២០.៤៦៩.៣៦៧ | - | - |
| **បំណុលសរុប** | **៦.១១៣.១៧៥** | **២៤.៩៧២.៣២២** | **៥.៦១៧.១០១** | **២៣.១២៥.៦០៤** |
| **មូលធន** | | | | |
| ដើមទុន | ១.៥០០.០០០ | ៦.០០០.០០០ | ១.៥០០.០០០ | ៦.០០០.០០០ |
| ទុនបម្រុងតាមបទប្បញ្ញត្តិ | - | - | - | - |
| ប្រាក់ខាតបង្គរ | (៥៥៧.១៧៣) | (២.២៧៧.៦៨៣) | (៤៨២.០៤៣) | (១.៩៦៨.៨៩៩) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | ១២៩.១៣១ | - | ១៥៩.៨២៨ |
| **មូលធនសរុប** | **៩៤២.៨២៧** | **៣.៨៥១.៤៤៨** | **១.០១៧.៩៥៧** | **៤.១៩០.៩២៩** |
| **បំណុល និងមូលធនសរុប** | **៧.០៥៦.០០២** | **២៨.៨២៣.៧៧០** | **៦.៦៣៥.០៥៨** | **២៧.៣១៦.៥៣៣** |

## ២. របាយការណ៍លទ្ធផលលម្អិត

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២៣

| | ២០២៣ | | ២០២២ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ចំណូលពីការប្រាក់ | ៩៣៨.០៤១០ | ៣,៨៥៥,៣៤៩ | ៣០៥.៤១២ | ១,២៤៨,២១៩ |
| ចំណាយលើការប្រាក់ | (៩៣.២៤) | (៣៨៣.២១៦) | (២៨.០៣៥) | (១១៤.៥៧៩) |
| **ចំណូលការប្រាក់សុទ្ធ** | ៨៤៥ | 3,472,133 | ២៧៧ | 1,133,640 |
| ចំណូលផ្សេងៗ | ៣៦.១២៧ | ១៤៨.៤៨២ | ២០០ | ៨១៧ |
| **ចំណូលប្រតិបត្តិការសរុប** | ៨៨០.៩២៨ | ៣,៦២០,៦១៥ | ២៧៧.៥៧៧ | ១,១៣៤,៤៥៧ |
| ការខាតបង់លើឱនភាពនៃឥណទានផ្តល់ដល់អតិថិជន | (៣០.៣៥២) | (១២៤.៧៤៧) | (៨៤.០៩៤) | (៣៤៣.៦៩២) |
| រំលស់ | (៧៤.៨៧៥) | (៣០៧.៧៣៦) | (៣៩.៣៣២) | (១៦០.៧៥០) |
| ចំណាយប្រតិបត្តិការ និងរដ្ឋបាល | (៨៣៩.៦៨៩) | (3,451,122) | (៥៦៨) | (២,៣២១,៦៦១) |
| ចំណាយពន្ធអប្បបរមា | (១១.១៤២) | (៤៥.៧៩៤) | (៣.៣) | (១៣.៤៨៧) |
| **ប្រាក់ខាតមុនដកពន្ធ** | (៧៥.១៣) | (៣០៨.៧៨៤) | (៤១៧.២០៩) | (១,៧០៥,១៣៣) |
| ចំណាយពន្ធលើប្រាក់ចំណេញ | - | - | - | - |
| **ប្រាក់ខាតសុទ្ធសម្រាប់ការិយបរិច្ឆេទ** | (៧៥.១៣) | (៣០៨.៧៨៤) | (៤១៧.២០៩) | (១,៧០៥,១៣៣) |
| **លទ្ធផលលម្អិតផ្សេងៗ** | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (៣០.៦៩៧) | - | ៤៩.១៩៦ |
| **សរុបលទ្ធផលលម្អិតសម្រាប់ការិយបរិច្ឆេទ** | (៧៥.១៣) | (៣៣៩.៤៨) | (៤១៧.២១) | (១,៦៥៥,៩៣៧) |

## ៣. របាយការណ៍ស្តីពីបម្រែបម្រួលមូលធន

សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២៣

| | ដើមទុន | | ប្រាក់ខាតបង្គរ | | លម្អៀងពីការប្តូររូបិយប័ណ្ណ | | សរុប | |
|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| នាថ្ងៃទី១ ខែមករា ឆ្នាំ២០២២ | ១.៥០០.០០០ | ៦.០០០.០០០ | (៦៤.៨៣៤) | (២៦៣.៧៦៦) | - | ១១០.៦៣២ | ១.៤៣៥.១៦៦ | ៥.៨៤៦.៨៦៦ |
| **លទ្ធផលលម្អិតសម្រាប់ការិយបរិច្ឆេទ** | | | | | | | | |
| ប្រាក់ខាតសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | - | (៤១៧.២០៩) | (១.៧០៥.១៣៣) | - | - | (៤១៧.២០៩) | (១.៧០៥.១៣៣) |
| ***លទ្ធផលលម្អិតផ្សេងៗ*** | | | | | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | ៤៩.១៩៦ | - | ៤៩.១៩៦ |
| **សរុបលទ្ធផលលម្អិតសម្រាប់ការិយបរិច្ឆេទ** | ១.៥០០.០០០ | ៦.០០០.០០០ | (៤១៧.២០៩) | (១.៧០៥.១៣៣) | - | ៤៩.១៩៦ | (៤១៧.២០៩) | (១.៦៥៥.៩៣៧) |
| នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | ១.៥០០.០០០ | ៦.០០០.០០០ | (៤៨២.០៤៣) | (១.៩៦៨.៨៩៩) | - | ១៥៩.៨២៨ | ១.០១៧.៩៥៧ | ៤.១៩០.៩២៩ |
| | | | | | | | | |
| នាថ្ងៃទី១ ខែមករា ឆ្នាំ២០២៣ | ១.៥០០.០០០ | ៦.០០០.០០០ | (៤៨២.០៤៣) | (១.៩៦៨.៨៩៩) | - | ១៥៩.៨២៨ | ១.០១៧.៩៥៧ | ៤.១៩០.៩២៩ |
| **លទ្ធផលលម្អិតសម្រាប់ការិយបរិច្ឆេទ** | | | | | | | | |
| ប្រាក់ខាតសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | - | (៧៥.១៣០) | (៣០៨.៧៨៤) | - | - | (៧៥.១៣) | (៣០៨.៧៨៤) |
| ***លទ្ធផលលម្អិតផ្សេងៗ*** | | | | | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | (៣០.៦៩៧) | - | (៣០.៦៩៧) |
| **សរុបលទ្ធផលលម្អិតសម្រាប់ការិយបរិច្ឆេទ** | - | - | (៧៥.១៣០) | (៣០៨.៧៨៤) | - | (៣០.៦៩៧) | (៧៥.១៣) | (៣៣៩.៤៨) |
| នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ | ១.៥០០.០០០ | ៦.០០០.០០០ | (៥៥៧.១៧៣) | (២.២៧៧.៦៨៣) | - | ១២៩.១៣១ | ៩៤២.៨២៧ | ៣.៨៥១.៤៤៨ |

# ៤. របាយការណ៍លំហូរសាច់ប្រាក់

សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២៣

| | ២០២៣ | | ២០២២ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | |
| ប្រាក់ខាតសុទ្ធសម្រាប់ការិយបរិច្ឆេទ | (៧៥.១៣) | (៣០៨.៧៨៤) | (៤១៧.២០៩) | (១.៧០៥.១៣៣) |
| *និយ័តភាពលើ៖* | | | | |
| ចំណាយពន្ធអប្បបរមា | ១១.១៤២ | ៤៥.៧៩៤ | ៣.៣០០ | ១៣.៤៨៧ |
| ការខាតបង់លើឱនភាពនៃឥណទានផ្តល់ដល់អតិថិជន | ៣០.៣៥២ | ១២៤.៧៤៧ | ៨៤.០៩៤ | ៣៤៣.៦៩២ |
| រំលស់ | ៧៤.៨៧៥ | ៣០៧.៧៣៦ | ៣៩.៣៣២ | ១៦០.៧៥០ |
| | ៤១.២៣៩ | ១៦៩.៤៩៣ | (២៩០.៤៨៣) | (១.១៨៧.២០៤) |
| *បម្រែបម្រួលនៃ៖* | | | | |
| ឥណទានផ្តល់ដល់អតិថិជន | (២៧៦.៤៧៧) | (១.១៣៦.៣២០) | (៦.០៩៣.៥៦៦) | (២៤.៩០៤.៤០៤) |
| ទ្រព្យសកម្មផ្សេងៗ | ៧.៥២៩ | ៣០.៩៤៤ | (១៦.៥២៧) | (៦៧.៥៤៦) |
| បំណុលផ្សេងៗ | (១៣.១៨៦) | (៥៤.១៩៤) | ១២១.៣០៤ | ៤៩៥.៧៦៩ |
| **សាច់ប្រាក់ប្រើប្រាស់ក្នុងប្រតិបត្តិការ** | (២៤០.៨៩៥) | (៩៩០.០៧៧) | (៦.២៧៩.២៧២) | (២៥.៦៦៣.៣៨៥) |
| ពន្ធអប្បបរមាដែលបានបង់ | (១១.០៨៩) | (៤៥.៥៧៦) | (២.៤៧៧) | (១០.១២៣) |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពប្រតិបត្តិការ** | (២៥១.៩៨៤) | (១.០៣៥.៦៥៣) | (៦.២៨១.៧៤៩) | (២៥.៦៧៣.៥០៨) |
| **លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | | | |
| ការទិញទ្រព្យ និងបរិក្ខារ | (២៣.៩៦៧) | (៩៨.៥០៤) | (១៧៨.៤៦០) | (៧២៩.៣៦៦) |
| ការទិញទ្រព្យសកម្មអរូបី | - | - | (១៩.២៥០) | (៧៨.៦៧៥) |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពវិនិយោគ** | (២៣.៩៦៧) | (៩៨.៥០៤) | (១៩៧.៧១០) | (៨០៨.០៤១) |
| **លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | | |
| សាច់ប្រាក់ទទួលបានពីប្រាក់កម្ចី | ៤៩៨.៣៤៦ | ២.០៤៨.២០២ | ៥.៤៤៤.៦៤៧ | ២២.២៥២.២៧២ |
| សាច់ប្រាក់ទទួលបានពីអនុបំណុល | ១០.៨៦១ | ៤៤.៦៣៩ | - | - |
| ការទូទាត់សងប្រាក់កម្ចី | - | - | ១៦១ | ៦៥៨.០០៧ |
| **សាច់ប្រាក់សុទ្ធទទួលបានពីសកម្មភាពហិរញ្ញប្បទាន** | ៥០៩.២០៧ | ២.០៩២.៨៤១ | ៥.២៨៣.៦៤៧ | ២១.៥៩៤.២៦៥ |
| **ការកើនឡើង/(ថយចុះ)សុទ្ធនៃសាច់ប្រាក់ និង សាច់ប្រាក់សមមូល** | ២៣៣.២៥៦ | ៩៥៨.៦៨៤ | (១.១៩៥.៨១២) | (៤.៨៨៧.២៨៤) |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាថ្ងៃទី ១ ខែមករា | ២៣០ | ៩៤៨ | ១.៤២៥.៩៧១ | ៥.៨០៩.៤០៦ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (១៣.១៩៨) | - | ២៥.៤៤៣ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាថ្ងៃទី ៣១ ខែធ្នូ ២០២៣** | ៤៦៣.៤១៥ | ១.៨៩៣.០៩១ | ២៣០.១៥៩ | ៩៤៧.៥៦៥ |

# IX. បណ្តាញការិយាល័យប្រតិបត្តិការ




១. ការិយាល័យកណ្តាល ក្រុងសិរីសោភ័ណ អាសយដ្ឋានស្ថិតនៅ៖ ផ្ទះលេខ ៦៦៨ ផ្លូវជាតិលេខ ៥ ភូមិគោរដ្ឋាន សង្កាត់អូរអំបិល ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ។
ទូរស័ព្ទ: ០១៥ ៤៨ ០០០០/០៦៩ ៤៦ ១១១១




២. សាខាស្រុកថ្មពួក មានអាសយដ្ឋានស្ថិតនៅ៖ ផ្ទះលេខ ២២៥ ផ្លូវជាតិលេខ៥៦A ភូមិផ្សារថ្មី ឃុំគំរូ ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ។
ទូរស័ព្ទ: ០១៥ ៤៨ ០០០០/០៦៩ ៤៧ ១១១១




៣. សាខាស្រុកវាលវែង មានអាសយដ្ឋានស្ថិតនៅ៖ ផ្ទះលេខ១៥៥ ផ្លូវជាតិលេខ ៥៥ ភូមិឯកភាព ឃុំថ្មដា ស្រុកវាលវែង ខេត្តពោធិ៍សាត់។
ទូរស័ព្ទ: ០១៥ ៤៨ ០០០០/០៦៩ ៤៨ ១១១១

# គ្រួសារ វ៉ាយ.អិល.ភី

**គ្រឹះស្ថាន វ៉ាយ.អិល.ភី មីក្រូហិរញ្ញវត្ថុ ម.ក**

អាសយដ្ឋាន៖ ផ្ទះលេខ ៦៦៨ ផ្លូវជាតិលេខ ៥ ភូមិគោរដ្ឋាន សង្កាត់អូរអំបិល ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ។

**សមាគមមូលនិធិមនុស្សចាស់**

អាសយដ្ឋាន៖ ផ្លូវជាតិលេខ ៥ ភូមិគោរដ្ឋាន សង្កាត់អូរអំបិល ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ។

**សមាគមមូលនិធិ វ៉ាយ.អិល.ភី**

អាសយដ្ឋាន៖ ផ្លូវជាតិលេខ ៥ ភូមិគោរដ្ឋាន សង្កាត់អូរអំបិល ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ។

# ដៃគូទំនាក់ទំនងអាជីវកម្មសំខាន់ៗរបស់គ្រឹះស្ថាន វ៉ាយ.អិល.ភី

**គ្រឹះស្ថាន វ៉ាយ.អិល.ភី មីក្រូហិរញ្ញវត្ថុ ម.ក**

ផ្ទះលេខ ៦៦៨ ផ្លូវជាតិលេខ៥ ភូមិគោរដ្ឋាន សង្កាត់អូរអំបិល

ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ

ទូរស័ព្ទលេខ៖ ០១៥ ៤៨ ០០០០

អ៊ីម៉ែល៖ info@ylpmicrofinance.com.kh

ហ្វេសប៊ុកផេក៖ YLP Microfinance PLC